# មជ្ឈមណ្ឌលឯកសារកម្ពុជា

## សម្ភាសន៍ជាមួយឈ្មោះ ឡូត សួយ ភេទប្រុស អាយុ៥៥ឆ្នាំ

## មុខងារជំនាន់ខ្មែរក្រហម«យោធា»

សព្វថ្ងៃរស់នៅភូមិប្រាសាទត្បែង ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ

ស្រុកកំណើតនៅភូមិជើងវត្ត ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបាត់ដំបង

ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១១

សម្ភាសន៍ដោយៈ ឡុង ដានី

០១ៈ៣៧ៈ៣៨

៦២ទំព័រ

ដានី ៖ ពូជំរាបសួរខ្ញុំចង់ស្គាល់ឈ្មោះពូ ឈ្មោះ ពេញអីដែរ?

សួយៈ ឈ្មោះខ្ញុំនោះ ។

ដានី ៖ បាទ ។

សួយៈ ឈ្មោះ ឡូត សួយ ។

ដានី ៖ ពូអាយុប៉ុន្មានហើយសព្វថ្ងៃ?

សួយៈ ៥៥ ។

ដានី ៖ ពូស្រុកកំណើតកើតជានៅក្នុងភូមិស្រុកអីដែរ?

សួយៈ នៅភូមិជើងវត្តយើងនេះ ។

ដានី ៖ ឃុំអីដែរហ្នឹង?

សួយៈ ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះយើងនេះ ខេត្តបន្ទាយមានជ័យ ។

ដានី ៖ ចឹងរាល់ថ្ងៃពូរស់នៅក្នុងភូមិឃុំស្រុកអីដែរ?

សួយៈ នៅភូមិប្រាសាទត្បែង ។

ដានី ៖ នៅភូមិប្រាសាទត្បែង?

សួយៈ បាទ ។

ដានី ៖ ឃុំអីដែរ?

សួយៈ ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ។

ដានី ៖ ខេត្តបន្ទាយមានជ័យដដែល?

សួយៈ បាទ! ខេត្តបន្ទាយមានជ័យ ។

ដានី ៖ ចុះប្រពន្ធពូឈ្មោះអី?

សួយៈ ឈ្មោះ ដាំ រ៉េត ។

ដានី ៖ សព្វថ្ងៃគាត់អាយុប៉ុន្មានដែរ?

សួយៈ ៥០ប៉ុន្មានទេ ៥០ប៉ុន្មានឯង ៥៦អីហ្នឹង ។

ដានី ៖ ៥១?

សួយៈ បាទ!៥១ហ្នឹង ។

ដានី ៖ ចុះមីងអ្នកស្រុកកំណើតណាដែរ?

សួយៈ នៅភូមិពោធិបុណ្យ ឃុំពន្លៃ ស្រុកភ្នំស្រុក ។

ដានី ៖ ឃុំពោធិ៍អី?

សួយៈ ឃុំពោធិ៍រំបុណ្យ ។

ដានី ៖ ពោធិ៍រំបុណ្យ?

សួយៈ បាទ ។

ដានី ៖ ចឹងសព្វថ្ងៃពូមានកូនប៉ុន្មាននាក់ដែរ?

សួយៈ ខ្ញុំកូន៦នាក់ ។

ដានី ៖ កូន៦នាក់?

សួយៈ បាទ ។

ដានី ៖ ស្រីប៉ុន្មានប្រុសប៉ុន្មាន?

សួយៈ ស្រីបីប្រុសបី ។

ដានី ៖ ពូសព្វថ្ងៃប្រកបមុខរបររកស៊ីអីដែរ?

សួយៈ ខ្ញុំធ្វើស្រែផង គ្រូមើលគេផង ។

ដានី ៖ គ្រូយ៉ាងម៉េចទៅលោកពូ?

សួយៈ មើលគ្រូវរបស់គេផង មើលស្តោះព្រោះ ។

ដានី ៖ អ!គ្រូខ្មែរ?

សួយៈ បាទ ។

ដានី ៖ ឪពុកពូឈ្មោះអីទៅ?

សួយៈ ឈ្មោះ ឡុត នុក ។

ដានី ៖ សព្វថ្ងៃគាត់នៅរស់ឬមួយស្លាប់ហើយ?

សួយៈ	នៅរស់ ។

ដានី ៖	គាត់រស់នៅណាឥឡូវ?

សួយៈ	នៅភូមិជើងវត្តយើងនេះ ។

ដានី ៖	នៅភូមិជើងវត្ត?

សួយៈ	បាទ ។

ដានី ៖	ចុះម្ដាយ?

សួយៈ	ម្ដាយ ណាប់ យួន ។

ដានី ៖	គាត់គាត់នៅណាដែរឥឡូវ?

សួយៈ	គាត់នៅរស់ទាំងអស់ ។

ដានី ៖	ឈ្មោះ ណាប់ យួន?

សួយៈ	ណាប់ យួន ។

ដានី ៖	ចុះពូបងប្អូនបង្កើតមានប៉ុន្មាននាក់?

សួយៈ	មាន៤នាក់ ។

ដានី ៖	ស្រីប៉ុន្មានប្រុសប៉ុន្មាន?

សួយៈ	ស្រីពីរប្រុសពីរ ។

ដានី ៖	ពូកូនទីប៉ុន្មាន?

សួយៈ	ខ្ញុំកូនទី៣ ។

ដានី ៖	កូនទី៣ ចុះកាលពីក្មេងៗពូរៀនសូត្របានដល់ណាដែរ?

សួយៈ	ខ្ញុំរៀនសូត្រថ្នាក់ទី៦ ។

ដានី ៖	រៀនថ្នាក់ទី៦ចាស់?

សួយៈ	បាទ ។

ដានី ៖	រៀននៅសាលាណា?

សួយៈ	សាលាយើងខ្ញុំប្រឡងទៅរៀនស្វាយបានប្រហែលជាមួយខែក៏ប៉ុល ពតចូល ។

ដានី ៖	អ ។

សួយៈ	ឈប់រៀន ។

ដានី ៖	ឈប់រៀនឆ្នាំ៧៥ហ្នឹងចឹងណឹស?

សួយៈ	បាទ ។

ដានី ៖ ចឹងប្រឡងចូលទៅរៀននៅស្វាយ?

សួយៈ បាទ!ខ្មែរក្រហមចូលក៏ គេរំដោះបានក៏គេបិតមិនឲ្យរៀនទៅឈប់រៀនពេលនោះទៅ ។

ដានី ៖ បាទ!កាលពូរៀននៅស្រុកនេះពូរៀននៅសាលាព្រះនេត្រព្រះ?

សួយៈ បាទ! ថ្នាក់ទី៧សាលាព្រះនេត្រព្រះយើងនេះ ។

ដានី ៖ ថ្នាក់ទី៧នៅព្រះនេត្រព្រះ ចឹងពូប្រឡងជាប់ថ្នាក់ទី៦ រៀននៅស្វាយរៀននៅសាលាណា?

សួយៈ សាលាលើភ្នំសព្វថ្ងៃមិនដឹងជាធ្វើស្អីទេ សព្វថ្ងៃ សាលាសម្តេចឪនៅភ្នំស្វាយ ។

ដានី ៖ អ!ចឹងលើភ្នំស្វាយហ្នឹង?

សួយៈ បាទ ។

ដានី ៖ ចឹងកាលហ្នឹងពូទៅរៀនបានតែមួយខែទេ បានបែកប៉ុល ពតចូលមកបណ្តោយទៅ?

សួយៈ បាទ ។

ដានី ៖ ចឹងពេលដែលប៉ុល ពតចូលមកឆ្នាំ៧៥ហ្នឹង ពូធ្វើអីទៀតទៅ?

សួយៈ គេឲ្យខ្ញុំទៅលើកទំបន់នៅព្រៃមាន់ លើកទំបន់ព្រៃមាន់គេរើសដាច់ខាតខ្ញុំក៏ដាច់ខាតហ្នឹងដឹងធ្វើអីទេ ខ្ញុំលើកគេ គេថាដាច់ខាតខ្ញុំក៏លើកដៃក៏គេយក យកខ្ញុំទៅក៏គេឲ្យធ្វើទ័ព ខ្ញុំថាដាច់ខាតធ្វើទ័ពតើសើច...ខ្ញុំក៏យំនឹកម៉ែ ខ្ញុំនឹកម៉ែក្រលួចអាយុ១៥ឆ្នាំខ្ញុំ គេយកទៅទុកក្នុងព្រៃយើង គេហៅព្រៃអូរស្នាច់ ស្នាច់តាខែកយើងនេះ រំដួលនេះបានគេដឹកទៅភ្នំលាប ដឹកទៅភ្នំលាបបានគេបំពាក់កាំភ្លើងឲ្យ ទៅនៅភ្នំលាបបានប្រហែលជាមួយខែបានគេដឹកមករំចេក ភ្នំស្រុកយើងនេះជាប់នៅរំចេកហ្នឹង ។

ដានី ៖ ចឹងពូកាលបែកឆ្នាំ៧៥ហ្នឹង គេឲ្យពូទៅលើកទំបន់នៅព្រៃមាន់?

សួយៈ បាទ ។

ដានី ៖ គេជ្រើសរើសយ៉ាងម៉េចកាលហ្នឹង?

សួយៈ គេកេណ្ឌយើងតាមភូមិថាឲ្យទៅលើកទំបន់ព្រៃមាន់ទាំងអស់គ្នា លើកភ្លឺចឹងណាស់ ទៅគ្រប់ភូមិទៅទាំងអស់ ។

ដានី ៖ អ ។

សួយៈ ដល់ទៅគេប្រជុំរកអ្នកដាច់ខាត ខ្ញុំមិនដឹងថាដាច់ខាតនោះធ្វើអីទេ ចេះតែលើកដៃតាមគេទៅ ។

ដានី ៖ ចឹងកាលពូទៅលើកទំនប់ព្រៃមាន់ហ្នឹងពីណាគេជាអ្នកគ្រប់គ្រងនៅហ្នឹង?

សួយៈ ប្រធានខ្ញុំតា ឃីម តា ឃីមយើងស្រុកកើតហ្នឹង ។

ដានី ៖ ស្រុកកើតស្រុកណាទៅស្រុកកើត?

សួយៈ	ខេត្តសៀមរាបយើងនេះណាស់ ។

ដានី ៖	ខេត្តសៀមរាប?

សួយៈ	បាទ !គេខាងនោះគេខាងជីរំដោះគេមកក្តាប់ប្រជាជនយើងខាងនេះ ។

ដានី ៖	កាលលើកទំនប់ប្រែមាន់ហ្នឹង លើកទំនប់ពីណាទៅណាទៅ?

សួយៈ	ទំបន់អមថ្នល់យើង ចាប់ពីរហាលទៅឃើញទំនប់តាមថ្នល់ណាស់ ។

ដានី ៖	បាទ ។

សួយៈ	អាហ្នឹងទំនប់ខ្ញុំលើកអាទំបន់អែមៗថ្នល់ហ្នឹង ខ្ពស់ហ្នឹងលើកអាហ្នឹងឯង ។

ដានី ៖	លើកបានរយៈពេលប៉ុន្មានទៅបានគេជ្រើសរើរកអ្នកដាច់ខាតហ្នឹង?

សួយៈ	លើកបានប្រហែលជាមួយខែ មួយខែក៏គេជ្រើសរើសអ្នកដាច់ខាត ។

ដានី ៖	អ្នកណាគេជាអ្នកមកជ្រើសហ្នឹង?

សួយៈ	ប្រធានទ័ពយោធាយើងហ្នឹងណាស់ យោធាកងបងសារឿនណាស់ ។

ដានី ៖	ពួកពីណាគេ?

សួយៈ	យោធាបងសារឿន ។

ដានី ៖	សារឿនហ្នឹងគាត់ធ្វើអី គាត់ធ្វើយោធាតែតួនាទីគាត់ធ្វើអី?

សួយៈ	គាត់យោធាគាត់ខាងកងធំទ័ព ។

ដានី ៖	របស់ស្រុកព្រះនេត្រព្រះឬក៏របស់តំបន់?

សួយៈ	កាលដើមឡើយតំបន់ណា ។

ដានី ៖	បាទ ។

សួយៈ	គេហៅទ័ពទំបន់ណាស់ ។

ដានី ៖	បាទ ។

សួយៈ	វរៈ៥១៣ ។

ដានី ៖	បាទ ។

សួយៈ	បានគាត់មករើសដាច់ខាតទាំងស្រីទាំងប្រុស ។

ដានី ៖	បាទ ។

សួយៈ	អ្នកណាក្រមុំដាច់ខាតក៏គេយកយើងប្រុសកំលោះក៏គេយកគេថាយកយុវជននិងនារី ។

ដានី ៖	បាទ ។

សួយៈ	ដាច់ខាតទាំងអស់គេយកទាំងអស់ ។

ដានី ៖ បាទ ។

សួយៈ ខ្ញុំលើកដៃក៏ជាប់ មិនដឹងជាប់ខាតធ្វើអី មិនបានសួរគេថាយកទៅធ្វើអីពុគេថាជាប់ខាតក៏លើក និងគេ ។

ដានី ៖ បាទ!កាលហ្នឹងគេជ្រើសរើសជាប់ខាតហ្នឹងអ្នកដែលទៅជាមួយពូមានគ្នាប៉ុន្មាននាក់ទៅ?

សួយៈ ខ្ញុំទៅគ្នាខ្ញុំមាន៥នាក់ ខ្ញុំមួយអាខ្មៅនៅបប៉ៃលិនមួយ អាវង់ស្លាប់ហើយមួយ អាវី មួយឡូតវី ជានគរបាលខេត្តនៅបន្ទាយមានជ័យមួយ ។

ដានី ៖ បាទ ។

សួយៈ ក៏អាសូរទីយើង ។

ដានី ៖ ពូសួរ ទី?

សួយៈ បាទ!ហ្នឹងហើយនៅជាប់ខាតជាមួយគ្នា ។

ដានី ៖ ដល់ពេលហ្នឹងគេជ្រើសរើសជាប់ខាតពូបានតែ៥នាក់ទេ នៅព្រៃមាន់ហ្នឹង?

សួយៈ បាទ ។

ដានី ៖ ដល់ពេលជ្រើសរើសបាន៥នាក់ចឹងទៅ ពេលហ្នឹងពូចូលទៅក្នុងវរៈ៥១៣ហ្នឹងទៅ?

សួយៈ បាទ ។

ដាវ៉ា ៖ វរៈអីហ្នឹង វរៈសេនាតូចឬវរៈសេនាធំ?

សួយៈ វរៈ៥១៣ហ្នឹងគឺវរៈសេនាតូចទេ ។

ដានី ៖ វរៈសេនាតូច ។

សួយៈ វាមានពីរវរៈ ។

ដានី ៖ បាទ ។

សួយៈ ម៉ាតំបន់វាមានពីរវរៈ ។

ដាវ៉ា ៖ វរៈមួយទៀតវរៈសេនាតូច?

សួយៈ វរៈ១៨ ។

ដានី ៖ ពីណាគេហ្នឹងជាប្រធានវរៈ?

សួយៈ វរៈ១៨ខ្ញុំអត់ស្គាល់ទេ គេនៅការពារព្រំដែនថៃជាមួយគ្នា ទៅឈរនៅខាងបឹង ។

ដានី ៖ ចឹងពេលពូចូលទៅកងទ័ពហើយយ៉ាងម៉េច យើងទៅឈរជើងនៅណាឬក៏បានហាត់កងទ័ព យ៉ាងខ្វះទៅ?

សួយៈ គេឈរជើងនៅភ្នំលាបក៏គេបង្ហាត់អក្សរ ខ្ញុំកុហក់គេថាខ្ញុំមិនចេះអក្សរទេ ។

ដានី ៖ បាទ ។

សួយៈ គេបង្ហាត់ឲ្យរៀនស្រះ"អ"ស្រះអា ស្រះអិ ស្រះអី ។

ដានី ៖ បាទ ។

សួយៈ រៀនតែប៉ុណ្ណោះឯងរៀនស្រះអស្រះអាស្រះអិស្រះអីរៀនរាល់ថ្ងៃ ។

ដានី ៖ បាទ ។

សួយៈ គេសរសេរអក្សរ"ក"ខ្ញុំថា ខ្ញុំមិនស្គាល់ទេ សរសេរស្រះអិខ្ញុំមិនស្គាល់គេឲ្យបង្រៀន ។

ដានី ៖ ចឹងយ៉ាងម៉េចបានជាពូកុហក់គេកាលហ្នឹង?

សួយៈ កុហក់គេព្រោះខ្លាចគេដឹងថាឯងអ្នកចេះគេយកទៅវៃចោល ខ្ញុំក៏កុហក់អាសួរទីក៏កុហក់ កុហក់ទាំងអស់គ្នា គេឲ្យសរសេរស្រះអ ស្រះអាចេះទៅ ពួកខ្ញុំទៅគាស់ដីបាតត្រពាំងអាជីសណាស់ ។

ដានី ៖ បាទ ។

សួយៈ យកផុកៗមកហាលធ្វើជីស យកមកសរសេរស្រះអស្រះអាស្រះអីយប់ឡើងឲ្យរាប់ ។

ដានី ៖ បាទ ។

សួយៈ ខ្ញុំក៏ចេះតែរាប់ៗដាក់ក្លាលើក្បាលលក់បណ្តោយមិនបានទេ ។

ដានី ៖ បាទ ។

សួយៈ ស្អែកឡើងសួរថាមិនដឹងទេ ។

ដានី ៖ បាទ!ពូរៀននៅភ្នំលាបហ្នឹងអស់រយៈពេលប៉ុន្មានទៅ?

សួយៈ រយៈពេលប្រហែលជា១០ថ្ងៃ ។

ដានី ៖ ១០ថ្ងៃហើយយ៉ាងម៉េចទៀតទៅ?

សួយៈ នៅ១០ថ្ងៃបានគេបញ្ជូនមកស្វាយ មកយាមស្វាយ យាមស្វាយបានបីថ្ងៃបានគេដឹកទៅគេរើសទ័ពបែកគ្នា ។

ដានី ៖ បាទ ។

សួយៈ បែកគ្នាបានខ្ញុំ បានខ្ញុំគេកាត់ទៅនៅស្រុកភ្នំស្រុក ។

ដានី ៖ បាទ ។

សួយៈ បានខ្ញុំទៅឈរជើងនៅដីភ្នំស្រុក ឈរជើងនៅភ្នំស្រុកបានគេបញ្ជូនខ្ញុំឲ្យទៅនៅភ្នំខ្វែង ភ្នំកូនខ្វែងយើងនេះ ។

ដានី ៖ កាលពូទៅយាមនៅស្វាយហើយគេបែងចែកទ័ពយ៉ាងម៉េច វរៈ៥១៣របស់ពូហ្នឹងគេបែងចែក
យ៉ាងម៉េចខ្លះ?

សួយៈ ៥១៣នេះ គេដកមកបំបែងឲ្យស្រុក ។

ដានី ៖ ចឹងឲ្យស្រុក?

សួយៈ បាទ!ឲ្យមកស្រុក ចែកមកស្រុកព្រះនេត្រព្រះផង ចែកទៅស្រុកភ្នំស្រុកផង ។

ដានី ៖ បាទ!ចឹងវរៈ៥១៣របស់ពូហ្នឹងគេបំបែកជាពីរ?

សួយៈ បាទ ។

ដានី ៖ គេបំបែកទៅស្រុកព្រះនេត្រព្រះមួយចំណែក គេបំបែកទៅស្រុកភ្នំស្រុកមួយចំណែក?

សួយៈ បាទ ។

ដានី ៖ ហើយពូទៅខាងស្រុកភ្នំស្រុក?

សួយៈ បាទ ។

ដានី ៖ ទៅស្រុកភ្នំស្រុកបានប៉ុន្មានទៅ?

សួយៈ ទៅស្រុកភ្នំស្រុកបានមួយកងធំ ។

ដានី ៖ បានមួយកងធំ?

សួយៈ បាទ!មួយកងធំហ្នឹងវាមិនបានពេញទេ ថាបានពេញចុះបានគ្នា៩០នាក់ ។

ដានី ៖ បាទ ។

សួយៈ សល់ប៉ុន្មានទៅខាងតំបន់ សល់ប៉ុន្មានទៅតំបន់វរៈ៥១៣សល់ទ័ពចាស់របស់គេ ។

ដានី ៖ បាទ!យល់ ។

សួយៈ គេទុក ។

ដានី ៖ ចឹងទៅស្រុកភ្នំស្រុកមួយកងធំ មកស្រុកព្រះនេត្រព្រះមួយកងធំ?

សួយៈ បាទ ។

ដានី ៖ ហើយសល់ប៉ុន្មានទៀតនៅក្នុងតំបន់?

សួយៈ បាទ!នៅក្នុងតំបន់គេដដែល ។

ដានី ៖ ចឹងនៅក្នុងកងធំរបស់ពូពីណាគេជាប្រធាន?

សួយៈ តា ណាក់ វងតាជន ។

ដានី ៖ ចឹងពូមានតួនាទីអីដែរ?

សួយៈ ខ្ញុំយុវជន ។

ដានី ៖ ចឹងពូយុវជន?

សួយៈ បាទ ។

ដានី ៖ ចឹងនៅខាងស្រុកព្រះនេត្រព្រះមានពីណាវិញ?

សួយៈ ស្រុកព្រះនេត្រព្រះយើងខ្ញុំស្គាល់មិនដល់អត់ ។

ដានី ៖ បាទ ។

សួយៈ ព្រោះបែងចែកគ្នារួចដឹកទាំងយប់ ។

ដានី ៖ ចឹងពូទៅខាងស្រុកភ្នំស្រុក?

សួយៈ បាទ ។

ដានី ៖ ពូយ៉ាងម៉េចទៅ កងធំពូធ្វើការងារអីខ្លះទៅនៅស្រុកភ្នំស្រុកហ្នឹង?

សួយៈ គេដល់បញ្ជូនរួចបានថ្នាក់លើគេឲ្យដកពួកខ្ញុំនេះទៅឈរជើងនៅកូនខ្វែង ។

ដានី ៖ បាទ ។

សួយៈ នៅនោះការពារភ្នំកូនខ្វែងគេហៅខ្សែត្រៀមទីពណាស់ ។

ដានី ៖ បាទ ។

សួយៈ នៅកូនខ្វែងនៅធ្មេញត្រី នៅឈូកអាង ។

ដានី ៖ បាទ ។

សួយៈ នៅភ្លើងទន្រ្ទាន ។

ដានី ៖ បាទ ។

សួយៈ ដាក់មួយក្រុមៗយាមខ្លាចបងប្អូនរត់ទៅថៃ ។

ដានី ៖ ចឹងពូទៅដាក់ខ្សែត្រៀមនៅភ្នំខ្វែងនៅឈូកអាងអីហ្នឹង អាហ្នឹងការពារកុំឲ្យ?

សួយៈ ចល័តរត់ទៅថៃ ។

ដានី ៖ ចឹងកុំឲ្យចល័តរត់ទៅថៃ?

សួយៈ បាទ!ខ្លាចគេរត់ ។

ដានី ៖ បាទ ។

សួយៈ ខ្ញុំនៅឈរជើងនោះរួចបានដកខ្ញុំមកវិញ ដកមកនៅជាមួយចល័ត ។

ដានី ៖ ពូឈរជើងយាមនៅហ្នឹងរយៈពេលប៉ុន្មាន?

សួយៈ នៅបានប្រហែលជាមួយឆ្នាំ អះមិនដល់មួយឆ្នាំទេ បានប្រហែលជាបីខែបានដកខ្ញុំមកអង្គភាពខ្ញុំវិញ ។

ដានី ៖ បាទ!ពូការពូឈរយាមនៅភ្នំខ្វែងហ្នឹង?

សួយៈ បាទ ។

ដានី ៖ រយៈពេលបីខែហ្នឹងចាប់ពីខែណាដល់ខែណាឆ្នាំណាដែរ?

សួយៈ ខ្ញុំចាប់យាមគិតមើលទៅចូលឆ្នាំរួច ចូលឆ្នាំរួចគេដកខ្ញុំទៅកូនខ្វែង ចូលឆ្នាំ៧៦ណាស់ ។

ដានី ៖ បាទ ។

សួយៈ ដើមឆ្នាំ៧៦ហ្នឹង ។

ដានី ៖ បាទ ។

សួយៈ ដកទៅកូនខ្វែងបានបីខែគេដកមកវិញ ដកមកកងតូច ដក់មកកងតូចគេឲ្យមកនៅអាងត្រពាំងថ្មនេះ ។

ដានី ៖ បាទ!ខ្ញុំចង់ដឹងកន្លែងពូយាមនៅភ្នំកូនខ្វែងណាស់?

សួយៈ បាទ ។

ដានី ៖ ចឹងសកម្មភាពកាលហ្នឹងមានកងចល័តរត់ទៅចូលមុខព្រួញខ្មែរក្រៀមរបស់ពូ ពូមានចាប់បានច្រើនទេកាលហ្នឹង?

សួយៈ អត់ដែលរត់ទេ ។

ដានី ៖ អត់ដែលរត់ទេ?

សួយៈ បាទ!ចល័តមិនដែលរត់ទេ ច្រើនតែរត់មានស្រុកឆ្ងាយៗនៅស្រុកយើងនេះរត់ ។

ដានី ៖ បាទ ។

សួយៈ រត់មិនដែលជួបទេ គេស្គាល់ភូមិសាស្ត្រព្រៃ នៅយាមយើងនៅយាមបាញ់តែឈ្លូសជ្រូកស៊ីប៉ុណ្ណោះឯង ។

ដានី ៖ អ ។

សួយៈ បើមានជាប់អន្ទាក់គេមានជាប់នៅព្រំដែននោះឯង ដែលគេដាក់ចំរ៉ូងអីហ្នឹង ពួកខ្ញុំយាមនៅខ្ទមចេះ ។

ដានី ៖ ចឹងភ្នំកូនខ្វែងនិងព្រំដែននៅឆ្ងាយពីគ្នាទៀត?

សួយៈ ឆ្ងាយណាស់ ។

ដានី ៖ ឆ្ងាយ?

សួយៈ ភ្នំកូនខ្វែងនៅជាប់អាងត្រពាំងថ្មយើងនេះ ។

ដានី ៖ បាទ ។

សួយៈ	ឃើញអាងឃើញភ្នំកន្លែងសប្បុរឈូសរមាំង ជ្រូកព្រៃ ។

ដានី ៖	ចឹងកាលហ្នឹងគេដាក់ខ្សែត្រៀមពីរខ្សែកន្លែងពូមួយនិងព្រំដែនមួយទៀត?

សួយៈ	បាទ!បីខ្សែត្រៀម ។

ដានី ៖	បី?

សួយៈ	បាទ!ដាក់កូនខ្មែររួចដាក់កណ្តាលហើយបានដាក់តាមក្រវ៉ាត់ព្រំដែន ។

ដានី ៖	បាទ ។

សួយៈ	ហើយគេដាក់អន្ទង់ ។

ដានី ៖	ចឹងកាលពូយាមនៅហ្នឹងពូមិនដែលបានចាប់បានអ្នកដែលរត់ទៅទេ?

សួយៈ	អត់ដែលបានជួបអត់ដែលបានចាប់ទេ ។

ដានី ៖	បាទ ។

សួយៈ	មិនដែលបានឃើញផង គេរត់យ៉ាងណាផង ឃើញចល័តវាមកឃើញវាសុំទៅដឹកខ្វាយអីជូនទៅដឹកយកទៅវិញទៅតែប៉ុណ្ណោះ ។

ដានី ៖	ចឹងមួយកងធំរបស់ពូយាមនៅហ្នឹង?

សួយៈ	បាទ!យាមនៅហ្នឹងតែបំបែកគ្នា ។

ដានី ៖	បាទ ។

សួយៈ	បំបែកមួយក្រុមៗនៅតាមខ្ទមធ្វើរ៉ូងចេះទៅ ។

ដានី ៖	បាទ ។

សួយៈ	សម្រាប់ទាក់ទងគ្នាចល័តបេះផ្សិត បេះបន្លែបន្ការអីទំពជូន ។

ដានី ៖	បាទ!ចឹងប្រទាប់ពីបីខែមកពូផ្លាស់មកវិញ?

សួយៈ	បាទ!ផ្លាស់មកនៅអាងត្រពាំងថ្មនេះវិញ ។

ដានី ៖	ខែណាឆ្នាំណាដែលពូបានផ្លាស់មកអាងត្រពាំងថ្មហ្នឹង?

សួយៈ	ខ្ញុំផ្លាស់នៅចុងឆ្នាំ៧៦យើងហ្នឹង ។

ដានី ៖	ចុងឆ្នាំ៧៦?

សួយៈ	បាទ ។

ដានី ៖	ខែប៉ុន្មានបើតាមពូស្មានមើល?

សួយៈ	អាខែក្រោយអាខែភ្លៀងទឹកលិចឡើងនេះណាស់ ខែទឹកឡើង ។

ដានី ៖	មិនដល់ខែកត្តិកអីទេ?

សួយៈ ទេ អាខែក្ខរយើងនេះ ប្រពន្ធនិយាយតថា ខែអាសាធ ។

ដានី ៖ ខែអាសាធអាចខែ៧ទៅខែ៨?

សួយៈ ខែជេសន៍ ។

ដានី ៖ ចឹងឥឡូវខែជេសន៍ហើយឥឡូវហ្នឹង?

សួយៈ ជេសន៍ហើយ ។

ដានី ៖ កាលពូទៅប្រហែលជាខែប៉ុន្មាន?

សួយៈ ខ្ញុំភ្លេចខែខ្ញុំចំណាំថាពួកខ្ញុំដើរមកវិញ ខែភ្លៀងទឹក ។

ដានី ៖ ទឹក?

សួយៈ បាទ!គេមកឲ្យធ្វើជំរុំនៅអាកាច់កែងអាងត្រពាំងថ្មយើងនេះ ។

ដានី ៖ បាទពូ!ចឹងមូលហេតុអីបានគេដកពូពីកន្លែងភ្នំកូនខ្វែងឲ្យមកនៅអាងត្រពាំងថ្មហ្នឹង?

សួយៈ ព្រោះគេឲ្យយាម ព្រោះបទបញ្ជាគេឲ្យយាមទំនប់ យាមទំបន់ខ្លាចយើងធ្វើមិនស្អាតឲ្យមានទ័ព គេនៅការពារត្រួតពិនិត្យ ធ្វើមិនស្អាតប្រាប់គេ គេឲ្យមកបំពេញវិញ ។

ដានី ៖ បាទ ។

សួយៈ ឬមួយទំនប់វាប្រេះវាបាក់ ។

ដានី ៖ បាទ ។

សួយៈ ប្រៀបបានថាដូច លោកប្អូនធ្វើរួចហើយទៅចេះ ខាងមុខវាប្រេះ ។

ដានី ៖ បាទ ។

សួយៈ បានខ្ញុំប្រាប់គេ គេធ្វើនិរសាទៅ សម័យនោះគេហៅនិរសាសំបុត្រ ។

ដានី ៖ បាទ ។

សួយៈ និរសាប្រែថាសំបុត្រនេះឯង ធ្វើសំបុត្រឲ្យទៅគេ ផ្ញើទៅគេគេមកដកកងចល័តមកបំពេញវិញ ឲ្យស្អាត ។

ដានី ៖ ចឹងពីណាគេមកបញ្ជាពូដកពូពីកូនខ្វែងមកវិញ មកខាងទំនប់ហ្នឹងណាស់?

សួយៈ អាហ្នឹងបញ្ជាការកងធំគេដក ។

ដានី ៖ បញ្ជាការកងធំ?

សួយៈ បាទ ។

ដានី ៖ តា ណាកអីហ្នឹង?

សួយៈ តា ណាកបញ្ជាការកងធំគេស្តាប់បញ្ជាខ្សែបណ្តាញរបស់គេពួកតា វ៉ាល់ ។

ដានី ៈ តា វ៉ាល់?

សួយៈ បាទ!តា វ៉ាល់បទបញ្ជាគេប្រើគេប្រាប់លោកប្អូនបេះ លោកប្អូនទទួលបញ្ជាប្រាប់ទៅពួកខ្ញុំដក
កំលាំងប៉ុណ្ណាៗយកមកបំពេញអានេះ នេះការទំនាក់ទំនងគ្នា ។

ដានី ៈ បាទ!ពេលហ្នឹងពូមានស្គាល់តា វ៉ាល់នៅពេលពូនៅកូនខ្មែរហ្នឹង?

សួយៈ ខ្ញុំរស់នៅជាមួយគាត់យូរគ្រាន់ដែរ ។

ដានី ៈ រស់នៅជាមួយគាត់តាំងពីពេលណា?

សួយៈ ពីឆ្នាំ៧៥ដែលគាត់បានប្រពន្ធគាត់ការតាំងពីឆ្នាំ៧៥ការនៅស្វាយ នៅរំដួល ។

ដានី ៈ ប្រពន្ធគាត់ការនៅឆ្នាំ៧៥?

សួយៈ បាទ!ចុងឆ្នាំ៧៥ ប្រពន្ធគាត់ការ ។

ដារ៉ា ៈ ការនៅណា?

សួយៈ ការនៅស្វាយចាប់ដៃគ្នា ។

ដានី ៈ បាទ!ប្រពន្ធគាត់ឈ្មោះអី?

សួយៈ ខ្ញុំភ្លេចប្រពន្ធគាត់ ។

ដានី ៈ យាយគឹមយាយគិន?

សួយៈ ភ្លេចឈ្មោះប្រពន្ធគាត់បាត់ គាត់ការជំនាន់គ្នាជាមួយតា ម៉ោងការដំណាលគ្នាហ្នឹង ។

ដានី ៈ បាទ ។

សួយៈ ការទាំងពីរនាក់ ។

ដានី ៈ ប្រពន្ធគាត់អ្នកស្រុកណា?

សួយៈ ប្រពន្ធគាត់មើល ភ្លេចប្រពន្ធគាត់មិនមែនជាអ្នកសៀមរាបទេ ប្រពន្ធគាត់និយាយចឹងៗដែរ ។

ដានី ៈ នៅណាមកពីខាងណា?

សួយៈ ខ្ញុំថាដូចជាមកពីខាងបាត់ដំបងប្រពន្ធគាត់ ។

ដានី ៈ បាទ!ចឹងថាស្គាល់គាត់តាំងពីឆ្នាំ៧៥ ពូមានប្រសាសន៍មិញថា៧៥ពូនៅខាងកងចល័តនៅព្រៃ
មាន់នៅធ្វើកងទ័ព?

សួយៈ ចុងឆ្នាំ៧៥ណាស់ ដើមឆ្នាំ៧៥ខ្ញុំនៅចល័ត ។

ដានី ៈ បាទ ។

សួយៈ ចុងឆ្នាំ៧៥ នេះខ្ញុំនៅទ័ព ។

ដានី ៈ បាទ ។

សួយៈ និយាយទៅក្នុងមួយឆ្នាំនេះឯង ។

ដានី ៖ បាទ ។

សួយៈ រើសទ័ពបានគាត់ កាលហ្នឹងអត់ចល័តទេ តា វ៉ាល់គាត់នៅប្រធានទ័ព ។

ដានី ៖ នៅជាប្រធានទ័ព?

សួយៈ បាទ!គាត់រងតា ភី ។

ដានី ៖ រងតា ភី?

សួយៈ បាទ ។

ដានី ៖ ចឹងកាលហ្នឹងគេជ្រើសរើទ័ពហ្នឹងពូទៅស្វាយហ្នឹងជួបគាត់នៅស្វាយឬជួបនៅណា?

សួយៈ ជួបគាត់នៅនេះឯងនៅរំដួលហ្នឹង គាត់អត់មាននៅស្វាយទេ គាត់នៅហ្នឹងរំដួល ។

ដានី ៖ បាទ ។

សួយៈ តា ម៉ោងគាត់នៅស្រុកព្រះនេត្រព្រះនេះ ។

ដានី ៖ បាទ ។

សួយៈ តា វ៉ាល់នៅរំដួលបានគាត់ការប្រពន្ធរួច តា ម៉ោងយកប្រពន្ធគាត់ផ្ទះគាត់នៅកាច់កែងជាប់យើងនេះ ប្រជាជនរាល់ថ្ងៃអាផ្លូវទៅជប់នេះ ។

ដានី ៖ នៅជប់វ៉ារីនេះ?

សួយៈ បាទ!ហ្នឹងផ្ទះតា ម៉ោង ។

ដានី ៖ បាទ ។

សួយៈ តា វ៉ាល់គាត់នៅរំដួល ។

ដានី ៖ រំដួលនៅណា?

សួយៈ នេះរំដួលព្រៃមាន់យើងនេះ ។

ដានី ៖ អ! ។

សួយៈ តែនិរសាគាត់ខ្មោចលោកវង់ៗនោះផាប់ អាវង់វាពួកម៉ាក់ខ្ញុំវ៉ានិរសាតា វ៉ាល់នេះឯង ។

ដានី ៖ បាទ ។

សួយៈ ពីរនាក់ខ្មោចអាឈ្លឹមនៅបំរើគាត់ ។

ដានី ៖ បាទ ។

សួយៈ នៅបំរើតាវ៉ាល់បានដល់ឆ្នាំ៧៦នេះ បានដកតាវ៉ាល់ចេញពីទ័ពក្តាប់ចល័តតំបន់ ។

ដានី ៖ ឆ្នាំ៧៦?

សួយៈ បាទ!ក្តាប់ចល័តម៉ាតំបន់៥ទាំងអស់ ។

ដានី ៈ បាទ!ចឹងគាត់ដកចេញពីទ័ព?

សួយៈ បាទ!ដកចេញពីទ័ពហើយគាត់ឈប់ពង្រឹងទ័ពហើយ ។

ដានី ៈ បាទ!កាលពីដំបូងតា ភីគាត់ជាប្រធានយោធាតំបន់៥?

សួយៈ បាទ ។

ដានី ៈ ហើយតា វ៉ាល់ហ្នឹងគាត់អនុយោធាតំបន់៥?

សួយៈ បាទ ។

ដានី ៈ ដល់ឆ្នាំ៧៦ហ្នឹងគេដកគាត់ចេញពីយោធាមកក្តាប់ចល័ត?

សួយៈ មកក្តាប់ចល័តទាំងអស់ ។

ដានី ៈ ចឹងមកក្តាប់ចល័តទាំងអស់?

សួយៈ បាទ ។

ដានី ៈ ចឹងគេដកពូពីកូនខ្វែងមកយាមទំនប់ហ្នឹង ពូថាខែភ្ជៀងឆ្នាំ៧៦?

សួយៈ បាទ ។

ដានី ៈ ខែភ្ជៀងហ្នឹង កាលហ្នឹងពូឃើញទិដ្ឋភាពយ៉ាងម៉េច កន្លែងត្រពាំងថ្មកាលពូមកដល់ដំបូង?

សួយៈ ខ្ញុំមើលទៅឃើញបើនិយាយពីរឿងទំនប់វាលើកវាមិនទាន់រួចណាស់ ចល័តវាច្រើន ចល័តវាច្រើនរត់ទៅផ្ទះចេះ បានពួកឈ្លបពួកអីហ្នឹង ពួកឈ្លបភូមិគេដាក់ខ្សែត្រៀមចាប់បញ្ជូនទៅវិញ បើរឿងផ្នែកទ័ពមិនដែលប៉ះពាល់រឿងចល័តអីទេ ។

ដានី ៈ អត់ទេខ្ញុំចង់ដឹងថា ពូចេញពីកូនខ្វែងមកត្រពាំងថ្មដំបូងណាស់?

សួយៈ បាទ ។

ដានី ៈ ពូកាលហ្នឹងទំនប់ហ្នឹងគេលើកហើយឬគេមិនទាន់លើកទេ កាលពូទៅដល់ដំបូង?

សួយៈ គេទើបចាប់ផ្តើមលើកវារួចម៉ាកង់ៗចឹងណាស់ ម៉ាឡូៗណាស់ ។

ដានី ៈ ពេលហ្នឹងពូឃើញយ៉ាងម៉េច លើកដីម៉េចវាមានរាងជាទំនប់ហើយឬមួយមិនទាន់មានអីទេ?

សួយៈ អត់ទេ គេកំពង់តែជីកហ្នឹង ជីករែករៀបចំជាទំនប់ទៅគេដាក់ខ្សែជាបង្គោលទៅណាស់ ។

ដានី ៈ បាទ ។

សួយៈ បាតក៏១៥ម៉ែត្រទៅកំពស់វា៥ម៉ែត្រទៅ ។

ដានី ៈ បាទ ។

សួយៈ ខ្នងលើវា៥ម៉ែត្រទៅ ។

ដានី ៖ តែកាលហ្នឹងពូទៅដល់ដំបូងហ្នឹងឃើញជាបង្គោលឃើញជាបុស្សិ៍អីមានឃើញជាដីទេ?

សួយៈ ដីផង អ្នកលើករួចមួយកន្លែងៗក៏រួចទៅអ្នកមិនទាន់រួចទៅចល័តវាមានកងពិសេសរបស់គេ ។

ដានី ៖ បាទ ។

សួយៈ មានកងពិសេសមានកងថ្មើរជើង ។

ដានី ៖ បាទ ។

សួយៈ កងពិសេសស៊ីមួយថ្ងៃពីរកំប៉ុងម្នាក់ ។

ដានី ៖ បាទ ។

សួយៈ កងស្មើជើងមួយថ្ងៃមួយកំប៉ុង ។

ដានី ៖ បាទ ។

សួយៈ កងពិសេសមួយម៉ែត្រគីបវែកតែ៨បង្គីទេ ៨អំវែក ។

ដានី ៖ មួយម៉ែត្រគីប?

សួយៈ មួយម៉ែត្រគីប៨អំវែក បង្គីប៉ុនៗនេះណាស់ ។

ដានី ៖ បាទ ។

សួយៈ បង្គីវែករត់ទៀតស្រីៗ រត់ឡើងបេះ ឡើងចាក់ៗអាហ្នឹងកងពិសេសគេ ។

ដានី ៖ ចឹងកាលពូទៅចុងឆ្នាំ៧៦ហ្នឹងមានឃើញគេវែកដីអីហើយ?

សួយៈ បាទ!វែកដីហើយ ។

ដានី ៖ បាទ ។

សួយៈ វែកដីឡើងដល់ឆ្នាំ៧៧ ពាក់កណ្តាលឆ្នាំចូលឆ្នាំ៧៨បានរួចទំនប់ ។

ដានី ៖ តែពូកាលហ្នឹងពូទៅដល់ដំបូងហ្នឹងពូឃើញថា កងចល័តណាខ្លះដែលធ្វើទំនប់ហ្នឹង កាលហ្នឹងពូថាតាវ៉ាល់គាត់ជាប្រធានកងចល័តតំបន់ ចឹងហើយមានកងចល័តណាទៀតក្រៅពីកងចល័តតំបន់ហ្នឹងធ្វើការនៅហ្នឹងដែរ?

សួយៈ អត់មានកងចល័តណាទេ សុទ្ធតែចល័តតំបន់ទាំងអស់ ព្រោះចល័តតំបន់បានន័យថាដូច បើយើងនិយាយទៅថាអ្នកធ្វើការនេះរាជការ អាមួយចល័តភូមិ ។

ដានី ៖ បាទ ។

សួយៈ អាមួយគេហៅចល័តសហករណ៍ ។

ដានី ៖ បាទ ។

សួយៈ ចល័តសហករណ៍នោះអត់មានក្របខ័ណ្ឌទេ ។

ដានី ៖ បាទ ។

សួយ៖ បើចល័តតំបន់គេមានគ្រូបវ័ណ្ណរបស់គេ មានពេទ្យតំបន់របស់គេមើល ។

ដានី ៖ បាទ ។

សួយ៖ ហើយមានមេធំគេទទួលខុសត្រូវទៀត បើច្បាប់ទំលាប់វាដូចទ័ពចឹងឯង ។

ដានី ៖ បាទ ។

សួយ៖ តែវាចល័តតែខោអាវគេបើកស្អាតៗដូចតែទ័ព ។

ដានី ៖ បាទ ។

សួយ៖ តែគេស៊ីបបូរហូបហៀវរបស់គេ ។

ដានី ៖ បាទ! ហើយវាមានមួយទៀតពូ កាលហ្នឹងពូទៅដល់ទំនប់ត្រពាំងថ្មហ្នឹង ពូដឹងថាកាលហ្នឹងទំនប់ត្រពាំងថ្មហ្នឹងដំបូងគេគ្រោងវាធ្វើហ្នឹង ពីណាគេជាអ្នកចាប់ផ្ដើមធ្វើទំនប់ហ្នឹង?

សួយ៖ អ្នកដែលចាប់គ្រោងធ្វើទំនប់ហ្នឹងនោះ ។

ដានី ៖ បាទ ។

សួយ៖ គឺផែនការមកពីថ្នាក់លើ មកពីតា វ៉ាល់ហ្នឹងបណ្ដោយ ។

ដានី ៖ មកពីតាវ៉ាល់?

សួយ៖ បាទ! មកពីតាវ៉ាល់គាត់មានគំរោងធ្វើជាអាងទឹក ។

ដានី ៖ ធ្វើជាអាងទឹក?

សួយ៖ បាទ! បើអាស្ពានធំនេះធ្វើមិនទាន់រួចនោះគេហៅជាងមូង ។

ដានី ៖ ជាងមូង?

សួយ៖ ជាងមូងធ្វើ គាត់ស្លាប់ហើយ ។

ដានី ៖ ជាងមូងហ្នឹងគាត់ធ្វើអី?

សួយ៖ គាត់មេជាងស្ពាន ។

ដានី ៖ មេជាងស្ពាន?

សួយ៖ ស្ពានធំធ្វើមិនទាន់រួចទេ ដែលមានបង្គោលច្រូងនោះ ។

ដានី ៖ ស្ពានធំនៅណា?

សួយ៖ ស្ពានធំនៅអាងត្រពាំងថ្មនោះ គេហៅស្ពានទី១ណាស់ ។

ដានី ៖ ស្ពានទី១ ហ្នឹងជាងមូងអ្នកធ្វើ?

សួយ៖ បាទ! ជាងមូងគាត់ធ្វើ ។

ដានី ៖ ចឹងក្រុមដាងមូងមានគ្នាច្រើនទេ?

សួយៈ មានកូនដាងគាត់មួយក្រុម តែខ្ញុំអត់ស្គាល់ឈ្មោះទេ ស្គាល់តែដាងមូងមួយទេ ។

ដានី ៖ បាទ ។

សួយៈ តែយើងរើសចល័តទៅអ្នកណានេះគាត់ទាញយកទៅជួយធ្វើគាត់ ។

ដានី ៖ បាទ!ចឹងទំបន់ហ្នឹងតា វ៉ាល់មានគំរោងធ្វើជាងអាងទឹក?

សួយៈ បាទ ។

ដានី ៖ គេធ្វើជាអាងទឹកធ្វើអី?

សួយៈ គេធ្វើជាអាងទឹកដើម្បីឲ្យប្រជាជនធ្វើស្រែប្រាំង ។

ដានី ៖ ធ្វើស្រែប្រាំង?

សួយៈ បាទ ។

ដានី ៖ ធ្វើស្រែប្រាំងហ្នឹងប្រជាជននៅកន្លែងណាដែលអាចធ្វើស្រែប្រាំងបាន?

សួយៈ ប្រជាជនយើងគ្រប់ម៉ាស្រុកភ្នំស្រុកយើងហ្នឹង ។

ដានី ៖ បាទ ។

សួយៈ ទឹកវាបាញ់មកទាំងអស់មកដល់ស្រុកព្រះនេត្រព្រះយើងនេះ ។

ដានី ៖ បាទ ។

សួយៈ ប្រឡាយទឹកមកដល់ឃុំរហាលយើងនេះ ។

ដានី ៖ បាទ ។

សួយៈ ហើយចាក់ទៅខាងនោះទៅស្ទឹងនោះ ។

ដានី ៖ បាទ!ចឹងហេតុបានជាពូដឹងថា តាវ៉ាល់ហ្នឹងជាដើមគំនិតជាអ្នកគ្រោងធ្វើទំនប់ហ្នឹង?

សួយៈ ពីព្រោះគាត់ អ្នកបញ្ជាហើយគាត់ជាអ្នកធ្វើការខុសត្រូវ គាត់ជាអ្នកវាស់វែង ។

ដានី ៖ បាទ ។

សួយៈ គាត់អ្នកវាស់វែងឲ្យធ្វើហើយគាត់អ្នកដឹកស្បៀងអ្នកណាក៏ស្តាប់បញ្ជារបស់គាត់ ។

ដានី ៖ បាទ ។

សួយៈ ត្រូវតែធ្វើមិនថាការស្ទូងដក ។

ដានី ៖ បាទ ។

សួយៈ ត្រូវបញ្ជាពីតា វ៉ាល់ ។

ដានី ៖ បាទ ។

សួយៈ ឲ្យស្ទួងស្រែនេះស្រែនោះឲ្យរួចអី គាត់ឲ្យធ្វើឲ្យរួចទំនប់ត្រង់ណាដែលបែកគាត់ធ្វើ ។

ដានី ៈ បាទ ។

សួយៈ គាត់ប្រាប់ឲ្យធ្វើ ។

ដានី ៈ បាទ ។

សួយៈ ព្រោះគាត់ធំជាងគេម៉ាតំបន់៥ យើងនេះ មានតែតាវ៉ាល់ទេធំជាងគេ ធំជាងគេដែលចល័តតំបន់ណាស់ ។

ដានី ៈ បាទ ។

សួយៈ គាត់ក្តាប់ទាំងអស់ម៉ាតំបន់៥ ហ្នឹង ។

ដានី ៈ បាទ ។

សួយៈ មានតែតាវ៉ាល់មួយទេ ។

ដានី ៈ បាទ ។

សួយៈ បានល្បីឈ្មោះគាត់គេហៅទំនប់តាវ៉ាល់ៗ ហ្នឹង ។

ដានី ៈ ទំបន់តា វ៉ាល់មួយណាទំនប់មួយណា?

សួយៈ ទំនប់តា វ៉ាល់មានទំនប់នេះមួយ ។

ដានី ៈ ទំនប់ពីកំបោរទៅស្រែះហ្នឹង?

សួយៈ បាទ!អាហ្នឹងទំនប់តា វ៉ាលដែលហ្នឹង អាអាងត្រពាំងថ្មនេះក៏ទំនប់តា វ៉ាល់ដែរ អាអាងស្ពានស្រែងនោះក៏ទំនប់តា វ៉ាល់ដែរ ។

ដានី ៈ បាទ ។

សួយៈ តា វ៉ាល់គាត់អ្នកធ្វើ ។

ដានី ៈ ចឹងគណៈតំបន់៥ ហ្នឹងពីណាគេជាគណៈតំបន់៥ ?

សួយៈ តា ហ៊ីង ។

ដានី ៈ តា ហ៊ីង?

សួយៈ បាទ ។

ដានី ៈ ចុះអនុតា ហ៊ីងមានពីណាទៀត?

សួយៈ ខ្ញុំអត់ស្គាល់គេអស់ទេ ដឹងអ្នកដែលធ្វើការមានតែតា ហ៊ីង តា ភី ក៏តា វ៉ាល់ តា ម៉ោង ។

ដានី ៈ បាទ ។

សួយៈ តា ម៉ោងពីដើមមិញគាត់ធ្វើការតំបន់ដែរ ។

ដានី ៖ បាទ ។

សួយៈ ដល់បានបែកមកបានគាត់មកកាន់ក្ដាប់ព្រះនេត្រព្រះនេះ ។

ដានី ៖ បាទ ។

សួយៈ ដល់ពេលរំលែកទ័ពបែកគ្នាគាត់នៅគណៈស្រុក ។

ដានី ៖ បាទ ។

សួយៈ កាលពីដើមមិញគាត់ជាមេទ័ពដូចគ្នាដែរ ។

ដានី ៖ បាទ ។

សួយៈ គាត់ឡើងមកប៉ុនរឿងវងតា ហ៊ីងខ្ញុំស្គាល់គ្នាអត់អស់ទេ ។

ដានី ៖ បាទ ។

សួយៈ ព្រោះយើងវាមិនបានជិតដល់ដូចថាព្រឹកល្ងាច ។

ដានី ៖ ចុះកាលធ្វើទំនប់ធ្វើអីហ្នឹងតា ហ៊ីងគាត់មានមកទេ?

សួយៈ គេមកដែរ គេមកទស្សនៈកិច្ច ទស្សនៈកិច្ចដូចថាគេមកមើលបានប៉ុណ្ណាអីប៉ុនណើ ពួកភ្ញៀវចិន ពួកអីមក គេថាអគ្គការៗហ្នឹងពួកចិន ។

ដានី ៖ បាទ ។

សួយៈ គេហៅប្រទេសស្អីនោះទេ គេមកបីប្រទេស ។

ដានី ៖ បាទ ។

សួយៈ មកគេមកពាក់អាវសដៃត្រឹមនេះ បើកឡានមកបើពួកខ្ញុំត្រៀមតាមអាងចេះមិនឲ្យបែរមុខចំទេ ឲ្យបែរខ្នងដាក់គេ បានន័យថាគេមិនឲ្យយើងយើងឃើញមុខគេណាស់ បែរតែខ្នងដាក់ទៅតែចេះ គេបើកឡានក្រោយខ្នងចេះ ។

ដានី ៖ បាទ ។

សួយៈ អាហ្នឹងគេថាពួកចិន និងប្រទេសណែ ប្រទេសមួយទៀតដែលមកមានពីរប្រទេស ។

ដានី ៖ ចឹងពូថាពួកចិនមកហ្នឹងមកឆ្នាំណា ខែណាឆ្នាំណាទៅ?

សួយៈ មកកាលឆ្នាំ៧៧ហ្នឹង ៧៧មក៧៦ក៏មកមួយឆ្នាំមកពីរដង ។

ដានី ៖ តែពេលពូទៅនេះហ្នឹងចុងឆ្នាំ៧៦?

សួយៈ បាទ!តែពូដំណឹងតែគេមកប៉ុនយើងនៅនោះ យើងត្រៀមអីព្រៃក៏ត្រៀម ។

ដានី ៖ តែពូបានឃើញគេដែលអត់?

សួយៈ ខ្ញុំឃើញតែក្នុងឆ្នាំ៧៧ទេ ។

ដានី ៖ បាទ ។

សួយៈ ៧៧ បានខ្ញុំដកមកបានឃើញ ។

ដានី ៖ ៧៧ ខែណាដែលពូឃើញហ្នឹង?

សួយៈ មកអាខែឃើងស្រូវមិនទាន់ដើមទេ ទើបពាក់កណ្ដាលដូវត្រឹមក្បាលជន្ទន់ហ្នឹង ។

ដានី ៖ បាទ ។

សួយៈ គេមកមើលស្រូវស្រែតាមសាលា គេហៅសាលាឆទានណាស់ ។

ដានី ៖ ចឹងកាលហ្នឹងពូចិនជិះអីមក?

សួយៈ ជិះឡាន ។

ដានី ៖ ជិះឡានគេម៉ាក់អីទៅ?

សួយៈ ឡានគេពិបាកប្រាប់អាឡានទាហានយើងអាស្អីគេ ដូចកុំម៉្មងការហ្នឹងឡាននោះឯង ។

ដានី ៖ ជិះមកមានគ្នាប៉ុន្មាននាក់?

សួយៈ មួយឡានមានគ្នាពីរនាក់ បើឡានក្តុបដូចឡានទេសចរណ៍យើងសព្វថ្ងៃក្តុបតូចណាស់ ។

ដានី ៖ បាទ ។

សួយៈ ដូចឡានទេសចរណ៍ចេះឯងតែវធុនតូច ។

ដានី ៖ បាទ ។

សួយៈ អានោះដឹកគ្នាច្រើន ។

ដានី ៖ បាទ!ចឹងពូនៅចិនមកចឹងពីណាគេជាអមដំណើរជាមួយចិនហ្នឹង?

សួយៈ ហ្នឹងពួកខាងតា ហ៊ុន ពួក តា ភី ហើយហ្នឹងទ័ពភូមិភាគគេឆ្កកអេសឆ្កក ។

ដានី ៖ អ!ចឹង ។

សួយៈ គេមានទ័ពពីរបក្ស ។

ដានី ៖ បាទ ។

សួយៈ អ្នកធំមកគេមិនឲ្យពួកតំបន់ការពារទេ គេឲ្យទ័ពភូមិភាគ ។

ដានី ៖ បាទ ។

សួយៈ ភាគនោះបើនិយាយទៅគេថាកងពិសេសរបស់ជាតិគេ ។

ដានី ៖ បាទ ។

សួយៈ គេថាអ្នកស្មោះត្រង់ ។

ដានី ៖ បាទ ។

សួយៈ អាវគេពណ៌អាចម៍សេះយើង ។

ដានី ៖ បាទ ។

សួយៈ គេហៅពួកភាគ ។

ដានី ៖ ពួកភាគ?

សួយៈ បាទ ៗ !ភាគនៅចំការគរយើងសព្វថ្ងៃ កន្លែងចំការគរនេះកន្លែងទីតាំងភាគនៅ ។

ដានី ៖ ចំការគរ?

សួយៈ ចំការគរស្វាយយើងនេះ ។

ដានី ៖ ចំការគរស្វាយហ្នឹង?

សួយៈ បាទ ។

ដានី ៖ អាហ្នឹងទីតាំងភាគនៅដែរ?

សួយៈ ទីតាំងភាគនៅមួយកងពល ។

ដានី ៖ កងពលរបស់ពីណាគេហ្នឹង?

សួយៈ ខ្ញុំអត់ដែលស្គាល់គ្នាទេ គ្រាន់តែដឹងថា គេពួកអាវរៈស្រុក៧ខ្ញុំដឹងថាវរៈវ៉ា វរៈស្រុក៧វ៉ានៅហ្នឹងមួយជួរភូមិតាដូនយើងហ្នឹង ដូនដាល ។

ដានី ៖ បាទ ។

សួយៈ អាហ្នឹងពួកភាគវរៈស្រុក៧ ។

ដានី ៖ បាទ ។

សួយៈ ខ្ញុំដឹងថាវរៈវ៉ាមិនថាកងពល វរៈគេក៏មិនដែលស្គាល់ឈ្មោះគេ ។

ដានី ៖ បាទ!ចឹងពូមានស្គាល់ភូមភាគទេ ភូមិភាគមានពីណាខ្លះ?

សួយៈ ភូមិភាគខ្ញុំស្គាល់តែ តា ញឹមមួយទេ ។

ដានី ៖ ស្គាល់តែតា ញឹមមួយទេ?

សួយៈ បាទ!តា ញឹមគាត់គណៈភូមិភាគ ។

ដានី ៖ គណៈភូមិភាគអ្នកផ្សេងទៀតអត់ទេ?

សួយៈ បាទ!អត់ស្គាល់ទេ ស្គាល់តែតា ញឹម គាត់ធ្លាប់មកប្រជុំ ។

ដានី ៖ គាត់មកប្រជុំឆ្នាំណា?

សួយៈ គាត់មកប្រជុំកាលឆ្នាំ៧៦ គាត់មកប្រជុំនៅភ្នំស្រុក ។

ដានី ៖ ប្រជុំនៅភ្នំស្រុក?

សួយៈ បាទ!ប្រជុំនៅសាលាស្រុកភ្នំស្រុកយើងនេះ ។

ដានី ៈ បាទ ។

សួយៈ នោះកន្លែងដាក់ទ័ពខ្មែរក្រហមពួកខ្ញុំនៅហ្នឹងឯង ។

ដានី ៈ បាទ!ចឹងកាលនៅត្រពាំងថ្មគាត់មានដែលមកទេ?

សួយៈ ទេ កន្លែងត្រពាំងថ្មដូចថាជាកន្លែងយើងកូនចៅយើងចេញទៅធ្វើការពួកអាងត្រពាំងថ្មអី តែទីតាំងអ្នកធំគេឈរជើងនៅកន្លែងភ្នំស្រុកហ្នឹងឯង កន្លែងសាលាស្រុកនោះណាស់ ពេលហៅពួកខ្ញុំដកមកវិញមកឈប់កន្លែងសាលាស្រុកនោះ ។

ដានី ៈ បាទ ។

សួយៈ នៅឃ្លាំងអង្ករឃ្លាំងអីបើក ក្នុងចូលឆ្នាំគេបើកសិទ្ធឲ្យយើងមកចូលឆ្នាំបីថ្ងៃដូចយើងចេះឯង ។

ដានី ៈ បាទ!ចេះពូដូចថាអ្នកដឹកនាំមកពីភ្នំពេញមកពីខាងមជ្ឈិមបក្សខាងអីខាងអ្នកធំៗពូមានដែលឮមានដែលឃើញពួកគាត់ចុះមកខាងទំនប់ត្រពាំងថ្មហ្នឹងដែលទេ?

សួយៈ ខ្ញុំឃើញខ្ញុំឮថាតែគេមក តែខ្ញុំមិនដែលស្គាល់ឈ្មោះ ប៉ុនយើងទ័ពចុះគេមិនដែលឲ្យយើងទៅជិតគេទេ ។

ដានី ៈ បាទ ។

សួយៈ ប្រៀបបានថា ដូចលោកប្អូនឯងអញ្ជើញមកដូចវត្តចេះ ពួកខ្ញុំនៅនេះហើយ ។

ដានី ៈ បាទ ។

សួយៈ នៅការពារមិនថាលោកណាមកដឹងថា គណៈភូមិភាគមកជាមួយ ដឹងថា តា ញឹមគាត់មកប៉ុននាក់ធំផ្សេងៗពួកភ្ញៀវចិនភ្ញៀវអីមក យើងដឹងថាពួកចិនមកហើយ ។

ដានី ៈ បាទ ។

សួយៈ ដឹងគ្នាយើងប្រាប់មកគេអូ គេប្រើគេអូអាសន៍រាំងសែងយើងប៉ុននេះ អាដាក់បង្គោលគេប្រាប់ឲ្យត្រៀមពួកភ្ញៀវចិនមកផងចេះឯង យើងក៏ត្រៀមទៅតែមិនដឹងជានរណាទេមកជាមួយ គេមកទស្សនៈមួយប្រាវគេឡើងឡានបិតខ្ញីបទៅវិញ ។

ដានី ៈ បាទ ។

សួយៈ គេទៅហូបបាយនៅស្វាយវិញ ។

ដានី ៈ អត់មានដែលឮថាឈ្មោះ ប៉ុល ពត អ្នកផ្សេងៗទៀតអីមកអីមានដែលឮទេ?

សួយៈ អត់ទេ ប៉ុល ពតអត់មានដែលឃើញមកដល់នេះទេ អត់ដែលមកទេ មិនដែលឮមកដល់ទេក្រែងលោមកត្រឹមស្វាយនោះមិនដឹងទេណាស់ ។

ដានី ៖ ចឹងអ្នកផ្សេងទៀត?

ស្លួយៈ អ្នកផ្សេងទៀតតែងពុមកដល់ នៅក្រោមគាត់ដែលពុ តែគាត់មិនដែលមកដល់ទេ ។

ដានី ៖ បាទ ។

ស្លួយៈ ព្រោះតំបន់ត្រង់នេះ តំបន់ភ្នំស្រុកតំបន់វាព្រៃណាស់ ។

ដានី ៖ បាទ ។

ស្លួយៈ គេមកគេមកត្រឹមតែត្រួតពិនិត្យនិងស្វាយ ។

ដានី ៖ បាទ ។

ស្លួយៈ នៅស្វាយចេះ ប៉ុល ពតមកស្វាយចេះទ័ពតាមថ្នល់នេះត្រូវត្រៀមបិតចរាចរណ៍មិនឲ្យប្រជាជនចេញ ។

ដានី ៖ ប៉ុល ពតមកស្វាយឆ្នាំណា?

ស្លួយៈ ទេ អត់ទេបានន័យថាខ្ញុំវាមិនដឹង ។

ដានី ៖ បាទ ។

ស្លួយៈ បើថាគេមកគេមកនៅហ្នឹងស្វាយ ព្រោះខ្ញុំនៅអាងត្រពាំងថ្មនេះ ។

ដានី ៖ បាទ ។

ស្លួយៈ យើងគិតតែមុខសញ្ញាយើង បើហ៊ានតែខុសគេយកយើងទៅវៃចោលហើយ បើថាយើងយាមទំនប់ចេះ បើបាក់ទំនប់យើងមិនរាយការណ៍ឲ្យគេ ទំនប់ហ្នឹងបាក់យ៉ាប់ ។

ដានី ៖ ចឹងពូនិយាយបកមកកន្លែងត្រពាំងថ្មវិញ ចឹងកន្លែងត្រពាំងថ្មបើតាមពូដឹងកងដែលលើកទំនប់ហ្នឹងប្រហែលជាប៉ុន្មានទៅ គិតជាកងធំកងវរៈវិញប៉ុន្មានទៅដែលលើកនៅត្រពាំងថ្មហ្នឹង?

ស្លួយៈ ចំនួនមនុស្ស ។

ដានី ៖ បាទ!គិតចំនួនមនុស្សគិតជាវរៈជាកងវិញ?

ស្លួយៈ ចំនួនមនុស្សរាប់ម៉ឺនណាស់ ។

ដានី ៖ រាប់ម៉ឺន?

ស្លួយៈ បាទ!រាប់ម៉ឺននាក់ ។

ដានី ៖ បាទ ។

ស្លួយៈ ព្រោះវាម៉ាតំបន់៥ ប្រមូលយកទាំងអស់ ។

ដានី ៖ បាទ ។

ស្លួយៈ យុវជននិងយុវនារី ។

ដានី ៖ បាទ ។

សួយៈ គេហៅយុវជននៅតាមភូមិករស្រុកកំណើតនៅថ្មពួកនៅស្រុកព្រះនេត្រព្រះ ស្រុកភ្នំស្រុកម៉ា តំបន់៥យកមកទាំងអស់ហើយ ចុះមកបងប្អូនថ្មីយើងដឹកមកពីភ្នំពេញមកទៀត ។

ដានី ៖ បាទ ។

សួយៈ មកច្រើនណាស់ ។

ដានី ៖ កាលហ្នឹងមានកងវរៈសេនាតូចវរៈសេនាធំទៅ?

សួយៈ បើនិយាយពីកងវរៈសេនាធំ ខ្ញុំចាំវាមិនបានអស់ខ្ញុំដឹងព្រោះមនុស្សវាច្រើនណាស់ ហើយខ្ញុំមិនស្គាល់គេអស់ផង ។

ដានី ៖ បាទ ។

សួយៈ គ្រាន់ដឹងថាចំនួនមនុស្សដែលនៅវាច្រើន ចាប់ពីអាងត្រពាំងថ្មនេះនៅទាល់ពន្លានោះ ។

ដានី ៖ ដល់ពន្លា?

សួយៈ បាទ!ដល់ពន្លាកំលាំងដែលលើកហ្នឹងដល់ពន្លា ។

ដានី ៖ បាទ ។

សួយៈ មានមនុស្សរាប់ម៉ឺន ។

ដានី ៖ បាទ ។

សួយៈ ហើយលោកប្អូនឯងដើរធ្វើការទៅមកចង់ភ្លឺមកវិញ ។

ដានី ៖ បាទ!ចឹងកាលហ្នឹងពូថាបាតក្រោមទំនប់ហ្នឹងរបវែងប៉ុន្មាន?

សួយៈ ១០បាត១៥ ។

ដានី ៖ ចឹងកំពស់?

សួយៈ កំពស់៥ម៉ែត្រ ។

ដានី ៖ កំពស់៥ម៉ែត្រចឹងខ្នងទំនប់?

សួយៈ ខ្នងវា៥ម៉ែត្រ ។

ដានី ៖ ចុះបណ្ដោយ?

សួយៈ បណ្ដោយវាមិនដឹង ។

ដានី ៖ ចឹងពីត្រពាំងថ្មទៅពន្លាដូចពូថាមិញនោះ?

សួយៈ បាទ!វាឆ្ងាយណាស់ អាចម៍ដីនោះឆ្ងាយណាស់ ។

ដានី ៖ ឆ្ងាយ?

សួយៈ បើយើងប៉ាន់ជាគីឡូជិត១០គីឡូ ។

ដានី ៈ ជិត១០គីឡូ?

សួយៈ បាទ! ព្រោះបិទប្រព័ន្ធទឹកចាក់មកពីព្រៃលើមកធ្វើជាអាង ។

ដានី ៈ បាទ ។

សួយៈ ដល់ពេលគេលែងត្រីគេដឹកមកយប់ ។

ដានី ៈ បាទ ។

សួយៈ គេលែងត្រីប្រាត្រីអីធំៗនោះគេចាក់លែងប្រហែលជា១០ឡាន ។

ដានី ៈ បាទ!អ្នកដែលនេះអ្នកដែលលើកទំនប់កងចល័តអីចឹងណាស់ មានបញ្ហាដូចពួកគាត់មាន សមាសភាពឬពួកគាត់ធ្វើការមានបញ្ហាអីចឹងពូអ្នកយាមអីចឹងយើងដូចថាគា វ៉ាល់បញ្ហោមកពូ ឲ្យពូហៅពួកគាត់និងទៅឬក៏យ៉ាងម៉េចកាលហ្នឹង?

សួយៈ ពេលមានបញ្ហាក្នុងកងក្នុងក្រុមរបស់គេ វរៈសេនាធំគេអ្នកធ្វើការគេមិនដែលទាក់ទងទ័ពទេ ។

ដានី ៈ បាទ ។

សួយៈ គេចង់ដូចជាថាអ្នកណាដែលងងឹតមាន់ចេះទៅ គេថាងងឹតសត្តិអារម្មណ៍ចឹងទៅបញ្ហោការកងធំឬកងតូចគេ កងធំគេដឹកមានអន្ទុងទៅបើហ៊ានតែដើរវេសអន្ទុងគេថាយើងមិនងងឹតមាន់ទេ អន្ទុងនោះបើថាធ្លាក់ហើយងាប់ហើយ ដើរគេចចេញ ។

ដារ៉ា ៈ ចឹងមានករណីនៅលើកទំនប់ត្រពាំងថ្មភាគច្រើនថាមានអ្នកដែលលើកហ្នឹងជួបបញ្ហាខ្វាក់មាន់មើលអត់ឃើញពេលយប់មែនទេ?

សួយៈ បាទ!ជួបបញ្ហាខ្វាក់មាន់ហ្នឹងហើយ ។

ដារ៉ា ៈ ហើយពេលដែលចង់ដឹងថា អ្នកហ្នឹងខ្វាក់មែនឬមិនខ្វាក់មែនហ្នឹង ។

សួយៈ បាទ ។

ដារ៉ា ៈ គេឲ្យដើរ?

សួយៈ បាទ!អ្នកជាគេដឹកដៃទៅ ទៅដល់អន្ទុងចេះគេដឹកចំអន្ទុងបើយើងខ្វាក់មែនដើរធ្លាក់អាហ្នឹងគេអោបចង្កេះទាញមកវិញ បានន័យថាយើងខ្វាក់មែន ។

ដារ៉ា ៈ បាទ ។

សួយៈ គេឲ្យសម្រាក ។

ដារ៉ា ៈ បាទ ។

សួយៈ បើយើងដឹកទៅឃើញអន្ទុងហើយដើរគេចចេញ អាអ្នកក្រោយប្រាទទម្លាក់ ។

ដានី ៖ ចឹងវិញ?

សួយៈ បាទ ។

ដានី ៖ ចឹងពូធ្លាប់ឃើញផ្ទាល់ភ្នែកអត់រឿងហ្នឹង?

សួយៈ ខ្ញុំឃើញហើយ ព្រោះវាមិនដែលទាក់ទងក្នុងទ័ពទេ ការងារវាធ្វើតែគ្នាវា ប្រជាជនដែលងាប់មិនងាប់ដោយស្នាដៃទ័ពទេ ជាស្នាដៃរបស់ប្រធានវរៈ ប្រធានវរៈសេនាធំកងធំ ។

ដានី ៖ បាទ ។

សួយៈ វាធ្វើបានខ្ញុំដឹងព្រោះស្រុកខ្ញុំនេះ ឈ្មោះ អា ឈួយៗនេះ ខ្ញុំឲ្យខោអាវខ្ញុំបើកខោអាវថ្មី បើខោអាវថ្មីខ្ញុំឲ្យវា អាឈួយវាសុំខ្ញុំថា សួយអើយឲ្យខោអាវមកអញមក អញការប្រពន្ធស្អែកខាតស្អែកហើយក៏ដោះខោអាវឲ្យវា យប់ឡើងគេយកវាទៅវៃចោល ។

ដានី ៖ អឺ ។

សួយៈ ចុះបើខ្ញុំឈរដើងនៅនោះឯង ដឹងថាគេយកអាឈួយទៅវៃចោល ដល់នេះគេសួរខ្ញុំមិត្តៗយប់គេចាប់មិត្តឈួយហើយ ខ្ញុំថាពីណាចាប់ ខ្ញុំអត់មានភមិត្តឯងទេ ថាទេ បានខ្ញុំថាអរពួកកងធំវរៈគេចាប់ ។

ដានី ៖ អឺ ។

សួយៈ បានខ្ញុំតាមដានទៅការដែលកាប់សម្លាប់អាផត្រពាំងថ្មនេះ អត់មានទ័ពទេ ជាប្រធានវរៈរបស់វា ប្រធានវរៈសេនាធំនិងកងធំរបស់វា ។

ដារ៉ា ៖ ជាកងចល័តហ្នឹង?

សួយៈ ជាកចល័តបានវាធ្វើរបាយការណ៍ឲ្យម៉ឺវា ។

ដានី ៖ ឲ្យពីណា?

សួយៈ ឲ្យម៉ឺវាដូចថាកងធំវាសម្លាប់ចេះវាធ្វើរបាយការណ៍ឲ្យវរៈសេនាធំ ឲ្យវរៈសេនាតូច អាសត្វនេះដល់វរៈសេនាតូច បើវរៈសេនាធំបើកងតូចវៃធ្វើរបាយការណ៍ឲ្យកងធំ កងធំបិតរឿងនេះ ។

ដារ៉ា ៖ ចឹងអត់មានបញ្ជូនទៅលើណាទៀតទេ?

សួយៈ អត់មានបញ្ជូនទេ ។

ដារ៉ា ៖ មានករណីមួយពូសេងគាត់និយាយថា មានគោ វ៉ាល់ហ្នឹងគាត់ដុតភ្លូកភ្លើងហើយពន្លត់ភ្លូកភ្លើងទៅនៅសល់រងើកវាក្រហមណាស់ ។

សួយៈ បាទ ។

ដារ៉ា ៖ ហើយឲ្យដឹកអ្នកដែលខ្វាក់មាន់ហ្វឹងដើរៗឲ្យដើរឆ្លងកាត់ភ្លូកភ្លើងហ្នឹង ហើយសិនជាខ្វាក់មាន់មែនដើរជាន់ភ្លើងហ្នឹង ។

សួយៈ បាទ ។

ដារ៉ា ៖ អ្នកដើរជាន់ភ្លើងក្នុងចំណោមហ្នឹងគឺមានគ្នាជាង១០នាក់ មានអ្នកជាន់ភ្លើងតែមួយនាក់ទេ ហើយម្នាក់ហ្នឹងនៅរស់គេអត់យកទៅវៃចោលទេ តែអ្នកដើរគេចភ្លើងគេយកវៃចោលអស់ អាហ្នឹងពូមានឃើញទេ ក្នុងករណីហ្នឹង?

សួយៈ អាហ្នឹងករណីវាអត់មានមកពីតា វ៉ាល់ទេ មកពីវរៈសេនាធំរបស់វា វាធ្វើគ្រប់កម្មវិធីទាំងអស់ ។

ដារ៉ា ៖ ចឹងអាជុតភ្លូកភ្លើងហ្នឹងពូមានបានឃើញផ្ទាល់ភ្នែកដែរឬយ៉ាងម៉េច?

សួយៈ ខ្ញុំមិនដែលឃើញទេ ខ្ញុំឃើញតែអន្លុង ។

ដារ៉ា ៖ ចឹងបើអន្លុងមាន?

សួយៈ ព្រោះខ្ញុំដឹងថាគន្ធឹះរបស់វាមកពីវរៈសេនាធំ ព្រោះតា វ៉ាល់គាត់ធ្វើយ៉ាងម៉េចកើតបើគាត់នៅតែស្វាយនេះ ។

ដានី ៖ អឺ ។

សួយៈ គាត់បានក្តាប់រួមចល័តម៉ាតំបន់៥មែន តែគាត់នៅស្វាយរងដូចជាគាត់ទុកចិត្តទៅលើប្រធានវរៈរបស់គាត់ ។

ដានី ៖ បាទ ។

សួយៈ ទុកចិត្តវរៈសេនាធំ ។

ដានី ៖ បាទ ។

សួយៈ គាត់ទោសចង់សម្លាប់អី នៅលើវរៈសេនាធំរបស់វា វាធ្វើទាំងអស់ភូមិខ្ញុំឈរជើងនៅអាងត្រពាំងថ្ម ក៏វាមិនដែលទាក់ទងទេ ។

ដានី ៖ ចឹង?

សួយៈ បាទ!បានខ្ញុំប្រាប់មិញថា ដែលវៃអាឈ្លួយយើងនៅភូមិជើងវត្តនេះ ចុះខ្ញុំឲ្យខោអាវវាល្ងាចនេះស្អែកឡើង ព្រឹកឡើងខ្ញុំមកផាប់អាឈ្លួយបាត់ហើយគេយកទៅវៃចោលបានខ្ញុំស្រាវជ្រាវដឹងថាវរៈសេនាធំវាវៃ ។

ដានី ៖ អឺ ។

សួយៈ ជួនកាលខ្ញុំអង្គុយលើខ្នងទំនប់ចេះគ្នាបីនាក់ចេះ វាដឹកគ្នាវាដឹកអាងងឹតមាន់ឲ្យដើរធ្លាក់អន្លុង ។

ដានី ៖ អឺ ។

សួយៈ ប៉ុនវាអត់មានទាក់ទងយើងទ័ពទេ គេធ្វើតែគ្នាគេ ។

ដារ៉ា ៖ ចឹងទ័ពអាចទាក់ទងនិយាយស្តីហាមឬក៏ឲ្យបញ្ញាឬយោបល់អីបានទេ ឃាត់បានទេ?

សួយៈ អត់ទេ អត់ឃាត់បានទេ យើងឃាត់វាខុសនៅតួនាទីរបស់គេ បើគេទាក់ទងយើង យើងធ្វើ គេមិនទាក់ទងស្រេចគ្នាគេ ខុសត្រូវនៅលើមេរបស់គេដោះស្រាយ ។

ដារ៉ា ៖ ចឹងពេលដែលពូទៅត្រពាំងថ្មពូអត់មានបានលើកដីលើកទំនប់អីទេ?

សួយៈ ខ្ញុំអត់មានបានលើកទេ ខ្ញុំនៅតែយាម ។

ដារ៉ា ៖ ចឹងពូទៅក្នុងលក្ខណៈជាទ័ព?

សួយៈ បាទ ។

ដារ៉ា ៖ ទៅគឺទៅការពារលើខ្នងទំនប់?

សួយៈ បាទ ។

ដារ៉ា ៖ លើទំនប់ត្រពាំងថ្មហ្នឹង?

សួយៈ បាទ!ខ្ញុំការពារឡើងរួច គេដកចល័តទៅអស់ពួកខ្ញុំនៅតែនោះឯងនៅខ្វាចវាបាក់ធ្វើរួចហើយ ទឹកវាជន់មកដល់ត្រឹមមាត់ចេះឯងហូរជ្រាបត្រង់ណាប្រាប់និរសាឲ្យទៅជួបគេឲ្យយកចល័តមក ថែម ។

ដារ៉ា ៖ ចឹងមិនមែនកងពូជាអ្នកជួសជុលអីថែមទេ?

សួយៈ បាទ!អត់ទេ ហ្នឹងចល័តគ្រាន់តែយើងប្រើតើពាក្យសម្តីទៅប្រាប់គេហៅគេឲ្យគេមកឲ្យគេថែម អាត្រង់នោះដាច់ អាត្រង់នេះចង់បាក់ អាត្រង់នោះប្រេះ គេដកមកមួយកងតូចមក មកថែ អានោះវិញ ។

ដានី ៖ ចឹងពូយើងជាកងទ័ពចឹងយើងមានតួនាទីមើលតែទំនប់ មើលទំនប់បាក់ទំនប់អីចឹងឬយើងការ ពារអីផ្សេងទៀត?

សួយៈ ស្អីផ្សេងទៀតក៏ការពារដែរ បើគេទាក់ទងយើងដូចយើងដើរធ្វើការចេះជួបមនុស្សដែលរត់ យើងចាប់ ។

ដានី ៖ បាទ ។

សួយៈ ចាប់ទៅយើងមិនអាចសម្លាប់គេបានទេ ។

ដានី ៖ បាទ ។

សួយៈ ចាប់បានបញ្ជូនទៅឲ្យមេថ្នាក់លើដោះស្រាយ ។

ដានី ៖ បាទ ។

សួយៈ គេធ្វើអីធ្វើទៅ ពួកខ្ញុំក៏មកវិញទៅ ។

ដានី ៖ ចឹងកាលហ្នឹងបើសិនជាមានអ្នករត់អីពួចាប់បញ្ជូនទៅថ្នាក់លើបញ្ជូនទៅថ្នាក់ណា?

សួយៈ បញ្ជូនទៅមេនៅអីភ្នំស្រុក បញ្ជូនទៅភ្នំស្រុក ។

ដានី ៖ ពីណាគេនៅភ្នំស្រុកហ្នឹង?

សួយៈ បញ្ជូនមកកងធំដូចជាតា ណាក ។

ដានី ៖ បាទ ។

សួយៈ បញ្ជូនមកគាត់ចេះ ពួកខ្ញុំទៅកន្លែងវិញ ។

ដានី ៖ មានអ្នករត់ច្រើនទេ ពេលដែលពូយាមហ្នឹង?

សួយៈ ប៉ុនតែខ្ញុំយាមមិនដែលបានជួបអ្នករត់ទេ ប៉ុនបើយើងនិយាយរួមទៅអ្នករត់ទៅខ្ញុំមិនដឹងព្រោះវាថានៅទំនប់ចេះដូនកាលវាដើរទៅបត់ដើងខាងនោះទំនប់ទៅ ។

ដានី ៖ អឺ ។

សួយៈ ពួកខ្ញុំដើរធ្វើការទៅទៀតទៅដឹងថាវាមកដឹងថាវាទៅទេ បើថាវាជាប់វាជាប់នៅខាងមុខនោះទៀតណាស់ ។

ដានី ៖ បាទ ។

សួយៈ តែកន្លែងដែលពួកខ្ញុំនៅវាវល់វិត្ថាណាស់ ។

ដានី ៖ អ ។

សួយៈ ដូចថារកមនុស្សល្អរកខ្មាំងវាអត់ដឹងទេ ព្រោះដូចថាប្អូនៗចេះខ្ញុំអង្គុយត្រង់នេះប្អូនដើរទៅនោះទៅបត់ដើងអីវត្តទៅ ។

ដានី ៖ អឺ ។

សួយៈ ខ្ញុំអង្គុយហ្នឹងមិនថាមកមិនថាទៅមែនទែន ។

ដានី ៖ ប៉ុន្តែក្រុមរបស់ពូមួយកងវរៈសេនាធំហ្នឹងមានដែលប្រជុំជាមួយតាវ៉ាល់ ហើយតាវ៉ាល់គាត់មានដាក់បទបញ្ជាអីយ៉ាងម៉េចៗទេ?

សួយៈ អត់ទេ គេប្រជុំតែកងធំ ប្រជុំតែតា ណាក តា ណាកគាត់ប្រជុំរួចបានគាត់ហៅកងតូចទៅប្រជុំ ។

ដានី ៖ បាទ ។

សួយៈ ប្រជុំរួចបានកងតូចហៅប្រធានក្រុមទៅប្រជុំ ត្រូវដាក់មុខសញ្ញាត្រង់ណា។ចេះឯងបានយើងបទបញ្ជារបស់គេដាក់ ។

ដានី : បាទ ។

សួយៈ ត្រូវថាដកខ្ញុំពីត្រង់នេះ ទៅឈរដើងនៅប៉ុស្តិ៍ចាស់ ទៅនៅឈរដើងនៅប៉ុស្តិ៍ចាស់ ។

ដានី : បាទ!ចឹងតួនាទីកងទ័ពដូជាពូចឹងយើងគ្រាន់តែដើរយាមទៅទំនប់ហ្នឹងហើយហ្នឹងមើលថា ទំនប់ណាបាក់ឬក៏មានបញ្ហាអី ទឹកចូលទឹកអីប្រាប់?

សួយៈ បាទ ។

ដានី : យើងផ្ញើសំបុត្រប្រាប់ទៅខាងណាហ្នឹង?

សួយៈ ផ្ញើសំបុត្រប្រាប់ទៅឲ្យមេ ។

ដានី : មេណា?

សួយៈ មេតា ណាក ។

ដានី : តា ណាក?

សួយៈ បាទ! បានតា ណាកផ្ញើសំបុត្រប្រគល់ឲ្យតា វ៉ាល់ ។

ដានី : បាទ!ចឹងក្រៅពីហ្នឹងយើងដើរយាមហ្នឹង ដូចថាក្នុងដូចជាពូចឹងយើងយាមប៉ុន្មានម៉ោងក្នុងមួយថ្ងៃចាប់ពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មាន?

សួយៈ ម្នាក់យើងយាមពីរម៉ោង ពីរម៉ោងមួយពួកមានបីនាក់ បីនាក់យាមពីរម៉ោង ។

ដានី : បាទ ។

សួយៈ ២ម៉ោងយើងដើរធ្វើការដូចថាដុបចេះដើរ ដើរទៅដល់ដុបចេះបកមកវិញមក ។

ដានី : បាទ ។

សួយៈ ដល់ម៉ោងដាស់អ្នកនេះម្តង ក្រោកដើរទៅ ។

ដានី : ចឹងមានបីនាក់ៗ?

សួយៈ បាទ!មួយពួកៗ ។

ដារ៉ា : ចឹងត្រូវតែមានអ្នកយាមចឹង២៤ម៉ោងតែម្តងពូ?

សួយៈ បាទ!យាមទាល់តែភ្លឺ ថ្ងៃយាមទៀតយប់យាមថ្ងៃយាម ។

ដារ៉ា : មានវេនគេ២ម៉ោងៗដូរគ្នារហូតចឹង?

សួយៈ បាទ!២ម៉ោងៗដូរគ្នា ខ្លាចទំនប់បាក់ ទំនប់បាក់យើងទទួលខុសត្រូវ ។

ដារ៉ា : ចឹងពេលដែលពូទៅដំបូងហ្នឹង គេកំពង់តែលើកទំនប់អីក៏ពូនៅហ្នឹងដែលមែនទេ?

សួយៈ បាទ ។

ដារ៉ា ៖ ចឹងយាមដែរ?

សួយៈ យាម ។

ដារ៉ា ៖ ចឹងម៉ាកន្លែងលើកទំនប់អាងត្រពាំងថ្មទាំងអស់ហ្នឹងមានកងទ័ពប៉ុន្មានវរៈដែលការពារនៅហ្នឹង?

សួយៈ អាយាមនៅត្រពាំងថ្មនោះមិនមានទ័ពទេចឹនទេ មានទ័ពតែមួយកងតូចទេ ទ័ពដាក់អីក្រោយ ដាក់កូនខ្មែងបានច្រើន ។

ដារ៉ា ៖ ចឹងមានតែកងតូចរបស់ពូទេ ដែលនៅអាងត្រពាំងថ្មហ្នឹង?

សួយៈ បាទ! កងតូចតា អាត ។

ដានី ៖ តា អាត?

សួយៈ បាទ ។

ដានី ៖ តា អាតគាត់ធ្វើប្រធានកងតូច?

សួយៈ បាទ ។

ដានី ៖ ប៉ុន្តែកងទ័ពហ្នឹងយើងដាក់ពីចុងទំនប់ដល់ដើមទំនប់ហ្នឹង?

សួយៈ អត់ទេ ដាក់តែមួយកន្លែងទេ ដូចថាទំនប់យើងស្ពានរន្ទះបាញ់ចេះ ។

ដានី ៖ បាទ ។

សួយៈ នៅស្រេះហ្នឹង ។

ដានី ៖ ប៉ុន្តែយើងដើរមើលទំនប់យើងមិនដើរសព្វ?

សួយៈ បាទ!ដើរដល់ពេលវេនយើង យើងដើរទៅដើរដល់កំបោរ ។

ដានី ៖ អឺ ។

សួយៈ មកពីកំបោរមកវិញ អត់មានដាក់ត្រង់នេះមួយកន្ទុំត្រង់នោះមួយកន្ទុំទេ ដាក់តែមួយកន្លែង ។

ដារ៉ា ៖ ចឹងកន្លែងហ្នឹងកន្លែងពូឈរជើងនៅកន្លែងណា?

សួយៈ ខ្ញុំឈរជើងនៅកាច់កែងយើងហ្នឹង អាំងត្រពាំងថ្មហ្នឹង ។

ដារ៉ា ៖ អាងកាច់កែងត្រពាំងថ្ម?

សួយៈ បាទ!អែមស្ពានទី១ណាស់ ។

ដារ៉ា ៖ អែមស្ពានទី១?

សួយៈ បាទ!អាកាច់កែងចេះមករួចមានស្ពាន អាកាច់កែងទៅស្រុកពង្រ ឥឡូវគេធ្វើសាលាឆទាន នោះ ។

ដានី ៖ បាទ ។

សួយៈ សាលាមុខបួននោះ ពីដើមមិញគេហៅសាលាមុខបួន ។

ដានី ៖ ចឹងកាលជំនាន់ប៉ុល ពតហ្នឹងមានសាលាមុខបួនហ្នឹង?

សួយៈ សាលាមុខបួនមួយនៅនោះឯង ។

ដានី ៖ សាលាមុខបួនហ្នឹងពីណានៅហ្នឹង?

សួយៈ សាលាមុខបួននេះនិយាយរួមទៅគេថាសាលាដំណាក់ សម្រាប់ទទួលភ្ញៀវ ។

ដានី ៖ អឺ ។

សួយៈ វាពីរអាមួយគេហៅសាលាមុខបួន មួយគេហៅសាសាទទួលភ្ញៀវ អានេះដូចថាសម្រាប់ទទួលភ្ញៀវមកពីភ្នំពេញ ដូចជាភ្ញៀវចិនភ្ញៀវហ្នឹង គេមកទស្សនៈកិច្ច គេទស្សនៈកិច្ចនៅសាលាទទួលភ្ញៀវហ្នឹងឯង គេមើលសភាពភូមិសាស្ត្រអាងភូមិសាស្ត្រផ្សេងៗទៅ ចំនួនមួយម៉ោងទៅគេបត់ទៅវិញ ។

ដាវ៉ា ៖ ចឹងអត់មានភ្ញៀវហ្នឹងដើរលើខ្នងទំនប់ត្រូវមើលទេ?

សួយៈ អត់ទេ អត់មានដើរលើទេ ព្រោះពួកវាមកពួកវាអត់មានប្រហែសខ្លួនទេ វាមកពាក់តែអាវសដៃខ្លីប៊ិននេះឯង ។

ដានី ៖ ពាក់អាវស?

សួយៈ បាទ!ពាក់អាវស វាមិនដែលដើរចេញឲ្យយើងឃើញវាខ្លាច ។

ដានី ៖ ចឹងពូកាលហ្នឹងហូបចុកយ៉ាងម៉េចដែរ ពូទ័ពរបបហូបចុកយ៉ាងម៉េចហើយពួកកងចល័តហូបចុកយ៉ាងម៉េច?

សួយៈ ទ័ពហូបមួយថ្ងៃពីរកំប៉ុង ។

ដានី ៖ ហូបមួយថ្ងៃពីរកំប៉ុង?

សួយៈ បាទ!ហូបមួយថ្ងៃពីរកំប៉ុង ។

ដាវ៉ា ៖ ហូបឆ្អែតគ្រប់គ្រាន់ដែលឬមួយយ៉ាងម៉េច?

សួយៈ គ្នាទាំងអស់គ្នាគ្រប់ហ្នឹង ១០នាក់ក៏១០កំប៉ុងហូបយ៉ាងម៉េចអស់ តែវាអត់តែម្សៅស៊ុប ។

ដានី ៖ បាស់?

សួយៈ អត់ម្សៅស៊ុប ។

ដានី ៖ អត់ប៊ីចេងម្សៅស៊ុប?

សួយៈ បាទ!អត់ប៊ីចេងដាក់តែអំបិលម្ជូរសន្ទឹកថ្មីង ។

ដារ៉ា :  អាហ្នឹងសុខភាពល្អវិញតើអត់បីចេនហ្នឹង ។

សួយៈ  សើច... ។

ដានី :  ចឹងបានន័យថាពួកគេចែករបបឲ្យមួយថ្ងៃពីរកំប៉ុងក្នុងម្នាក់ៗ ?

សួយៈ  បាទ ។

ដានី :  ហើយដល់ពេលម្ហូបយើងមានត្រីមានសាច់អីហូបគ្រប់គ្រាន់ដែលឬយ៉ាងម៉េច?

សួយៈ  ម្ហូបដោះស្រាយខ្លួនឯងថ្ងៃណាខ្វះទៅអត់ក៏អំបិលយើង ។

ដានី :  បាទ ។

សួយៈ  អត់មានម្សៅស៊ុបទេ ដាក់អំបិលគ្រួសយើងប៉ុនៗនេះមកនាំគ្នាគេសទៅសើច... ។

ដានី :  បាទ!ចុះបើកងចល័តវិញយ៉ាងម៉េច?

សួយៈ  កងចល័តវាមានសេដ្ឋកិច្ចរបស់គេ  គេមានតែវាអត់បបូរណាស់  គេបើកទៅដូចថា១០០នាក់ទៅគេបានដូចថាសាច់គោឬសាច់ជ្រូកសាច់ត្រីមួយគីឡូទៅណាស់  គេដាក់បន្លែឲ្យច្រើនទៅ ។

ដានី :  តែអង្ករយ៉ាងម៉េចអង្ករម្នាក់ប៉ុន្មានដែលតាមពូដឹង  កាលហ្នឹង?

សួយៈ  បើកងពិសេសវាបានម្នាក់ពីរកំប៉ុង ។

ដានី :  បាទ ។

សួយៈ  ដូចទ័ពដែរ  ហ្នឹងកងពិសេសបើកងវាយរងកងធម្មតា  គេហៅកងថ្មើជើងនោះ  អានោះមួយកំប៉ុងក្នុងមួយថ្ងៃ ។

ដានី :  មួយថ្ងៃមួយកំប៉ុង?

សួយៈ  បាទ!ម្នាក់មួយថ្ងៃមួយកំប៉ុង  ព្រឹកកន្លះកំប៉ុងល្ងាចកន្លះកំប៉ុង ។

ដានី :  ចឹងពូអាកងពិសេសហ្នឹងគេជ្រើសកងចល័តយ៉ាងម៉េច  កងពិសេសហ្នឹងកងយ៉ាងម៉េច?

សួយៈ  កងពិសេសនេះបើយើងនិយាយទៅថា  ថាកងដាច់ខាតថាងាប់ចោលដូចខ្ញុំថាចឹងមួយម៉ែត្រគីបគេវែកតែ៨អំវែកឲ្យអស់ ។

ដានី :  អឺ ។

សួយៈ  មួយម៉ែត្រគីបបួនជ្រុងជំរៅមួយម៉ែត្រវែក៨អំវែកឲ្យអស់  ហើយរត់ឡើងទៀត  វែករត់ទៀតបន្តិវាប៉ុនៗនេះដាក់ឡើងទៀត ។

ដានី :  អឺ ។

សួយៈ  វែករត់ចេះបន្តិវាប៉ុនៗនេះដាក់ឡើងកំពង់វែករត់  អានោះគេហូបឆ្ងាញ់ខោអាវក៏ល្អ ។

ដានី :  ចឹងកងពិសេសហ្នឹងគេជ្រើសបានប្រហែលជាប៉ុន្មានទៅក្នុងកងចល័តដែលធ្វើហ្នឹង?

សួយៈ  កងពិសេសហ្នឹងមានមួយកងធំរបស់វា ។

ដានី ៈ  មួយកងធំ?

សួយៈ  បាទ!មានតែមួយកងធំទេ ។

ដានី ៈ  មួយកងធំមានប៉ុន្មាននាក់?

សួយៈ  មួយកងធំមាន១០០នាក់ ។

ដានី ៈ  ចឹងមានតែ១០០នាក់ទេចឹង?

សួយៈ  បាទ ។

ដានី ៈ  ចឹងពូមានប្រសាសន៍មានមួយម៉ឺនជាងហ្នឹងមានតែ១០០នាក់ទេ ដែលជាកងពិសេសហ្នឹង?

សួយៈ  បាទ!កងពិសេសហ្នឹងវាមានតែ១០០ទេ ដែលគេរើសហ្នឹង ផុតពីនោះមានតែធម្មតាដូចយើង ថាចល័តធម្មតាអានោះរាប់ម៉ឺននាក់ ហ្នឹងធម្មតាទេដូចថាលើកមួយម៉ែត្រគឺបចឹងទៅបួន៥នាក់ ១០នាក់ទៅ អានោះរបបវាតិច ។

ដានី ៈ  របបតែមួយថ្ងៃមួយកំប៉ុងទេ?

សួយៈ  បាទ!មួយថ្ងៃមួយកំប៉ុងទេ អាគេស្មគ្រចូលកងពិសេសនេះគេមានរបបច្រើន ។

ដានី ៈ  អឺ ។

សួយៈ  ហើយខោអាវស្បៀកពាក់អីវាសម្បូរជាងគេ ។

ប្រុញ ៈ  ពូអ្នកដឹកនាំកងពិសេសហ្នឹងពីណាគេ ប្រធានកងធំ?

សួយៈ  កងពិសេសខ្ញុំអត់ស្គាល់គេទេ ខ្ញុំស្គាល់តែរងគេឈ្មោះមិត្តរៀប ។

ប្រុញ ៈ  ឈ្មោះ រៀប?

សួយៈ  បាទ!រងប្រធានអត់ស្គាល់ទេ មិត្តរៀបនៅស្រុកទ្រៀសយើងនេះ ។

ដានី ៈ  បាទ ។

សួយៈ  ទ្រៀសនៅផ្គាំ ។

ដានី ៈ  គាត់នៅរស់ទេពូ?

សួយៈ  មិត្តរៀបហ្នឹងមិនដឹងជាទៅណាទេ សព្វថ្ងៃ ។

ដានី ៈ  បាទ!ចឹងពូមនុស្សរាប់ម៉ឺននាក់ទៀតហូបបានមួយថ្ងៃតែមួយកំប៉ុងម្នាក់ទេ?

សួយៈ  បាទ!មួយថ្ងៃមួយកំប៉ុង ។

ដានី ៈ  កាលហ្នឹងពូឃើញយ៉ាងម៉េចដែលទិដ្ឋភាពពេលហ្នឹង ហូបចុកមើលទៅឃើញរូបរាង ឃើញ កាយវិការគាត់យ៉ាងម៉េចដែលពេលហ្នឹង?

សួយៈ រូបរាងគាត់ក៏ស្គមដែលហូបមិនឆ្អែត គ្មានរស់ជាតិខ្លះទៅស្ពឹក ខ្លះទៅក្បាលជន្ទង់ធំជាងក្បាល ខ្លះរកតែស្គរធ្វើថ្នាំមិនបានទៀត ។

ដានី ៈ រកអីគេ?

សួយៈ រកស្គរធ្វើថ្នាំស្ពឹកមិនបាន អ្នកខ្លះគ្នាដេកទៅគ្នាអស់ពេក ខ្លះទៅគេឲ្យសែងអាចម៍សែងអីធ្វើជី ខ្ញុំសាកខ្លួនខ្ញុំហើយខ្ញុំសែងអាចម៍ មួយខែឲ្យខ្ញុំសែងអាចម៍មិនធ្វើគេវ៉ៃចោល សែងអាចម៍ឲ្យក្រអូមអាចម៍ អត់មានស៊ុយទេ ក្រអូមទៅវិញ ព្រោះអាចម៍ហ្នឹងវាចាញ់ដេះ ។

ដានី ៈ អឺ ។

សួយៈ ចាក់ដេះរួចសែងអត់មានស្អុយទេ អានេះដែលខ្ញុំធ្លាប់សែងណាស់ ។

ដារ៉ា ៈ ចុះយ៉ាងម៉េចទ័ពគេឲ្យទៅសែងវិញ?

សួយៈ គេឲ្យយើងលុតដុំឲ្យគេដឹងថា ទ័ពជាគំរូ ។

ដានី ៈ អ ។

សួយៈ ជាគំរូដឹកនាំប្រជាជន កុំឲ្យធ្វើតែគេ យើងមិនធ្វើវាអត់មាន ។

ដារ៉ា ៈ ទ័ពដឹកនាំអីពេលលើកទំនប់អីទ័ពអត់ហ៊ានឲ្យយោបល់អត់ហ៊ានថាយ៉ាងម៉េចផងហ្នឹង?

សួយៈ អាមួយផ្នែករបស់គេ បើយើងនិយាយជំទាស់ត្រូវវាល្អ បើខុសគេយកយើងទៅវ៉ៃចោល ។

ដានី ៈ អឺ ។

សួយៈ មកពីខ្ញុំនិយាយចេះឯងបានជាគេយកខ្ញុំទៅវ៉ៃចោលម្ដងរត់នៅឃុំព្រះនេត្រព្រះយើងនេះ ។

ដានី ៈ អឺ ។

សួយៈ ខ្ញុំជួយប្រជាជនខ្ញុំខ្លាចខ្ញុំឈប់ជួយបណ្ដោយ ។

ដារ៉ា ៈ ជួយយ៉ាងម៉េចពូនិយាយឡើងវិញ?

សួយៈ បងធំខ្ញុំប៉ាអាដាននេះ គាត់ដាំថ្នាំ ។

ដារ៉ា ៈ បាទ ។

សួយៈ ដានយើងនេះណាស់ ។

ដារ៉ា ៈ បាទ ។

សួយៈ ដាំថ្នាំដក់ចឹងទៅគាត់ហាន់ ឈ្លបនិរតីគេចាប់ ចាប់ទៅខ្ញុំក៏ថា មិត្តឯងចាប់ធ្វើអីគាត់ ពេលម៉ោងសម្រាកហ្នឹងឯងគាត់ដាំផងបានដក់ ។

ដារ៉ា ៈ បាទ ។

សួយៈ គាត់ដាំបានមិត្តឯងយកទៅចាក់ចោលចាប់របស់គាត់ យើងធ្វើការចឹងដែលត្រឹមត្រូវ ដូចម្តាយធំខ្ញុំទៀតដូចគាត់ហូបបាយមិនបានចឹងណាស់ ។

ដារ៉ា ៖ បាទ ។

សួយៈ គេដួសមួយវែកគាត់ហូបបានតែបន្តិច គាត់ហាលទុកដល់ពេលគាត់ឈឺគាត់យកអាអង្ករគ្រៀមហ្នឹងមកបបរ ។

ដារ៉ា ៖ បាទ ។

សួយៈ ចាប់របស់គាត់ដល់នេះគេថា ពួកខ្ញុំពាយ័ព្យខ្លាំង ខ្លាំងយប់ឡើងគេចាប់ខ្ញុំយកទៅវៃចោល ។

ដារ៉ា ៖ ចាប់បានទេ?

សួយៈ ចាប់បាន ។

ដារ៉ា ៖ ចាប់យកទៅវៃនៅណា?

សួយៈ ចាប់យកទៅវៃកន្លែងតា ក្រុកនេះ គេហៅតាក្រុកនេះចាប់ខ្ញុំយកទៅឃុំហ្នឹង ។

ដារ៉ា ៖ កន្លែងវត្តហ្នឹង?

សួយៈ ទេ អាកាច់កែងនេះ មានក្លោងទ្វារវត្ត ក្លោងទ្វារវត្តភ្នំយើងនេះ ។

ដារ៉ា ៖ អ! ហើយចុះម៉េចអាចរត់ផុតបាន?

សួយៈ ខ្ញុំវៃតវិញ ។

ដារ៉ា ៖ ចឹង?

សួយៈ បាទ ។

ដារ៉ា ៖ វៃតយ៉ាងម៉េចទៅ?

សួយៈ គ្នាគេ១៥នាក់ គេចាប់ខ្ញុំ ខ្ញុំអង្គុយគេហៅខ្ញុំ ហៅម៉ែខ្ញុំឃើញមិត្តសួយទៅណា ខ្ញុំឆ្លើយបាទ ពូប្រធានភូមិឲ្យទៅជួប ។

ដារ៉ា ៖ បាទ ។

សួយៈ ខ្ញុំថាទៅចុះ ខ្ញុំដឹងស្រាប់ថាម៉ែគេចាប់ខ្ញុំហើយ ។

ដារ៉ា ៖ អឺ ។

សួយៈ គេចាប់ខ្ញុំបាត់ហើយ ខ្ញុំដាក់ស្បែកជើងកង់ឡានឲ្យតឹង ខ្ញុំពាក់អាវបេះខ្ញុំគិតឃើញថា វៃមីនេះសិន ។

ដានី ៖ ស្រីៗ?

សួយៈ បាទ ។

ដារ៉ា ៖ អ ៗ

សួយៈ ស្រីៗនិរតីនេះ ខ្ញុំថាវ៉ៃមីនេះសិន ទៅដល់ផ្ទះប្រធានភូមិចុះមកឲ្យប្រុសអាវគេត្រឹមៗនេះ ដឹកចុះវាស៊ីបាយផាត់គ្រហើរៗ ។

ដារ៉ា ៖ អឺ ៗ

សួយៈ ឃើញខ្មែរមួយចង្វាយមកចាប់ខ្ញុំ ខ្ញុំមិនបាននិយាយខ្ញុំដាក់តែកន្ទុយភ្នែកមើល ខ្ញុំថាបងនាំខ្ញុំមកផ្ទះប្រធានភូមិទៅណាទៀត គេថាមកវត្តយើងនេះហើយ ។

ដារ៉ា ៖ អឺ ៗ

សួយៈ ដល់មកវត្តខ្ញុំដើរមកដល់មុខវត្ត ដល់កន្លែងផ្សារយើងនោះអត់នាំចូលវត្តឃើញចេញពីវត្ត៥នាក់ទៀត ។

ដារ៉ា ៖ អឺ ៗ

សួយៈ វាបាន១០នាក់ ១០នាក់វាថាតោះទៅកន្លែងឃុំ មេឃុំនេះឈ្មោះ មី កំផលៗមេឃុំស្រីនិរតី ខ្ញុំទៅដល់ផ្ទះមេឃុំនោះឃើញប្រុលមកការ៉ាវគេ ខ្ញុំថាអីយ៉ាចាប់បាត់ ខ្ញុំគិតថាធ្វើម៉េចចេះ ខ្ញុំក៏បែរមកថា បងខ្ញុំសុំទៅនោមមួយភ្លេត ប្រាប់គេត្រង់ថាសុំទៅនោម អានិរតីថាពូទៅបត់ជើងក្នុងបង្គន់ទៅ ខ្ញុំថាខ្ញុំមិនចេះបត់និងបង្គន់ទេ ស៊ុយខ្ញុំបត់តែវាល ។

ដារ៉ា ៖ អឺ ៗ

សួយៈ ខ្ញុំស្មាទោសធ្វើជាកាន់ក្តបែរ វាចាប់ដៃខ្ញុំចាប់ដៃខ្ញុំវ៉ៃមាំងបណ្តោយ វ៉ៃមកហឹៗ ខ្ញុំវ៉ៃសម្លឹងមើលឈ្មោះ មីជឿននិរតីទាប ដាក់មីនេះមួយឲ្យនៅមួយសិនអញ ហេមកខ្ញុំវ៉ៃដាំងមួយដៃមួយដៃមកទៀតអោបចង្កេះខ្ញុំ អោបចង្កេះខ្ញុំថាអីយ៉ាងមីនេះធ្វើមែនទែន ខ្ញុំចាប់ក្បាលបានលេងជង្គង់ត្រូវដោះអ៊ុកក្តិតហ្នឹងដី ហើយកាប់ខ្ញុំពីក្រោយកាប់ភ្លឹបរហែកតែអាវ ទេវតាលោកជួយមិនបានមុតទេ កាប់រឹបៗមិនបានត្រូវទេ តា ក្រកវ៉ៃខ្ញុំម៉ាជុនទល់ដៃពីរដាក់ខ្ញុំយកសៀតថ្កា ខ្ញុំលើបផុត គេចមកវិញលែងតាក្រកមួយដើងបាំងជាប់រទេះ ជាប់រទេះចឹងខ្ញុំថា អញស៊ូគេមិនបានទេ ថ្ងៃពេញបោរ ហត់ពេកខ្ញុំរឹងរត់ៗឡើងភ្នំនេះ រត់ទៅដល់មុខភ្នំឡើងទៅដល់ក្លោងទ្វារកាច់ដល់ថ្មល់រត់ឡើងភ្នំ ។

ដារ៉ា ៖ អឺ! ៗ

សួយៈ មកចូលភូមិខ្ញុំដើងវត្តបានរត់ទៅប្រពន្ធខ្ញុំប្រធានពេទ្យស្រុក ។

ដារ៉ា ៖ អឺ ៗ

សួយៈ ប្រធានពេទ្យស្រុកភ្នំស្រុកឲ្យប្រពន្ធខ្ញុំព្យាបាលមួយខែចុះខ្ញុំធ្វើសំបុត្រចេញពីប្រធានវរៈចេញពីកងធំមកសំបុត្រត្រាក្រឡង់ កាលនោះគេចាប់និរតីអស់ហើយ អះ! គេចាប់ពាយ័ព្យអស់នៅសល់ពួកខ្ញុំ១០០នាក់ ។

ដារ៉ា ៖ អឺ ។

សួយៈ នៅក្នុងព្រៃ ព្រៃកូនខ្វែងនេះព្រោះខ្ញុំដកពីអាងត្រពាំងថ្មទៅនៅក្នុងព្រៃវិញ ដែលគេចាប់ពាយ័ព្យចាប់តា ញឹម ចាប់តា ភី តា ហ៊ុង ។

ដារ៉ា ៖ ក្នុងឆ្នាំណាដែលចាប់ហ្នឹង?

សួយៈ ចាប់នៅក្នុងចុងឆ្នាំ៧៨ ។

ដារ៉ា ៖ អឺ ។

សួយៈ បានខ្ញុំរត់ទៅក្នុងព្រៃវិញដល់រត់រួចបានដល់ចូលឆ្នាំ៧៩នេះបានខ្ញុំដកមកវិញ មកហ្នឹងស្រុកប្រពន្ធខ្ញុំ ។

ដារ៉ា ៖ អឺ ។

សួយៈ បានខ្ញុំរត់មកខ្មែរមកខាងនេះ ខ្ញុំធ្វើជាទាហានយួនជាមួយគេ ។

ដារ៉ា ៖ ចឹងពូធ្វើជាទាហានរដ្ឋកម្ពុជាវិញទៀត?

សួយៈ បាទ ។

ដារ៉ា ៖ ចឹងទៅវៃជាមួយខ្មែរក្រហមវិញទៀតចឹង?

សួយៈ ខ្ញុំទៅវៃជាមួយវាទៅវៃជាមួយខ្មែរក្រហមវិញ វៃម៉ាជួរត្រង់នេះឯង ។

ដារ៉ា ៖ ចឹងមុនដំបូងទ័ពខ្មែរក្រហមទៅការពារនៅទំនប់?

សួយៈ បាទ ។

ដារ៉ា ៖ អាងត្រពាំងថ្ម?

សួយៈ បាទ ។

ដារ៉ា ៖ ដល់ពេលទ័ពវៀតណាមចូលមកចូលជាមួយទ័ពវៀតណាមវៃខ្មែរក្រហមវិញ?

សួយៈ បាទ! ខ្ញុំវៃខ្ញុំឃើញយាយចែមរត់ ខ្ញុំវៃយាយ ចែមធ្លាក់យាយចែម ។

ដារ៉ា ៖ ចឹងវិញទៀត?

សួយៈ បាទ ។

ដានី ៖ ពូខ្ញុំចឹងបន្តទៀត ចឹងពូនៅយាមដល់ត្រពាំងថ្មហ្នឹងដល់ពេលណា?

សួយៈ ខ្ញុំយាមអាងត្រពាំងថ្មដល់ឆ្នាំ៨៨នេះ ។

ដារ៉ា ៖ ពូយាមដល់៧៨ឬ៨៨ពូ?

សួយៈ ខ្ញុំឈប់ហើយ ។

ដារ៉ា ៖ ៧៨ឬ៨៨បញ្ឈាក់មួនទៀតពូ?

សួយៈ ៧៨ ។

ដារ៉ា ៖ ៧៨ ។

សួយៈ ៧៨ហ្នឹងពួកកំពង់ចាមមកហើយ ។

ដានី ៖ ខែប៉ុន្មានដែលពូយាមនៅអាងត្រពាំងថ្មហ្នឹង?

សួយៈ មិនដឹងខែប៉ុន្មានអីប៉ុន្មានទេ ភ្លេចអស់ ដឹងថាពួកកំពង់ចាមនិងពួកតា កែវគេហៅនិរតីៗណាស់ ។

ដានី ៖ និរតី?

សួយៈ បាទ ។

ដានី ៖ ចុះនិរតីមកខែណាឆ្នាំណា?

សួយៈ ខ្ញុំភ្លេចបាត់សួរប្រពន្ធខ្ញុំបានដឹង វាទៅសុំថ្នាំប្រពន្ធខ្ញុំហ្នឹងឯងវាលីក្រវ៉ាវចូលទៅសុំខាងពួកកំពង់ឆ្នាំងណាស់ ។

ដារ៉ា ៖ អឺ ។

សួយៈ និរតីវាមានពីរបក្សអាមួយខាងនិរតីភូមិភាគនិរតីនេះ ។

ដារ៉ា ៖ បាទ ។

សួយៈ មួយបក្សកំពង់ឆ្នាំងលាយពោធិសាត់នេះវាមួយបក្ស ។

ដានី ៖ ហ្នឹងពួកបស្ចឹមអីពូ?

សួយៈ បាទ!អាហ្នឹងពួកបស្ចឹមហើយពួកកកោះបាត់ដំបងនេះ គេហៅពួកនិរតីដែរ ។

ដារ៉ា ៖ អឺ ។

សួយៈ វាមានពីរបក្សអាបក្សមួយដក់តែស្លឹកសង្កែ អះ!ដក់តែស្លឹកកកោះ ដក់ស្លឹកកកោះនោះអាហ្នឹងអាតា កែវនិរតី ។

ដារ៉ា ៖ អឺ ។

សួយៈ ពួកនិរតីកាចណាស់ បើពួកកកោះកំពង់ឆ្នាំងស្លុត ស្រីៗដូចគ្នាបើពួកតា កែវកាចណាស់ បើពួកកកោះកំពង់ឆ្នាំងស្លុត ។

ដានី ៖ បាទ!ចឹងពួកលាលដែលពួដកចេញពីកន្លែងត្រពាំងថ្មហ្នឹង ពួកនិរតីចូលមកហើយបានពួដកចេញឬយ៉ាងម៉េចពេលហ្នឹង?

សួយៈ ពេលដែលគេចាប់ពាយ័ព្យ ។

ដានី ៖ គេចាប់ពាយ័ព្យ?

សួយៈ បាទ!គេចាប់ពាយ័ព្យ គេចាប់ប្រធានភូមិភាគបាន ។

ដារ៉ា ៖ បាទ ។

សួយៈ ចាប់ភូមិភាគហ្នឹងគេហៅទៅប្រជុំ ។

ដារ៉ា ៖ បាទ ។

សួយៈ ភូមិភាគបូព៌ានិងភូមិភាគពាយ័ព្យយើងនេះ គេថាភូមិភាគបូព៌ានោះវាបាញ់ទូតចិនងាប់ តាម៉ុកនេះជាអ្នករករឿងថា ពួកពាយ័ព្យបាញ់ ។

ដារ៉ា ៖ អឺ ។

សួយៈ ដល់ដឹកទ័ពយើងតំបន់៥នេះ ដឹកសម្រុកចូលព្រៃកូនខ្វែងទាំងអស់ ។

ដារ៉ា ៖ អ ។

សួយៈ ដឹកចូលព្រៃ ។

ដានី ៖ ពេលហ្នឹង តា ម៉ោង តាវ៉ាល់អីគេចាប់ហើយនៅ?

សួយៈ អត់ទាន់ចាប់ទេ ។

ដានី ៖ គេមិនទាន់ចាប់ទេ?

សួយៈ បាទ!គាត់គេចខ្លួនខាងទ័ពវិញ កាន់ទ័ពឲ្យប្រជាជនចល័តគាត់នៅតែកាន់ចេះតែដូចគាត់លែងចោលចេះណាស់ ។

ដារ៉ា ៖ បាទ ។

សួយៈ គាត់ទុកមួយកន្ទុំ ប្រជាជនចល័តធ្វើការធ្វើទៅខាងផ្នែកដើរនយោបាយទ័ព ពួកទ័ពទាំងអស់ទៅនៅនិងព្រៃនៅកូនខ្វែងកាំភ្លើងធំអីដាក់នៅកូនក្អែង ។

ដារ៉ា ៖ អឺ ។

សួយៈ ដល់ពេលចាប់តា ញឹមបានហ្នឹង តា ញឹមគណៈភូមិភាគពាយ័ព្យនេះ ចាប់តា ញឹមបានយកតា ញឹមទៅរៀន សម័យប៉ុល ពតគេថារៀនគឺងាប់ហើយជាប់គុកហើយ ។

ដារ៉ា ៖ បាទ ។

សួយៈ ដល់ពេលនេះបានគេមកគ្នាវាមានតែ១៥នាក់ទេ មកចាប់តំបន់៥ យើងនេះទ័ពរាប់រយនាក់ មកតែ១៥នាក់ មកដល់ហៅមេក្មេងហៅតា ហ៊ឹងទៅប្រជុំ ។

ដារ៉ា ៈ បាទ ។

សួយៈ ហៅតា ហ៊ឹងទៅប្រជុំចាប់តា ហ៊ឹងបានដាក់លើផ្ទះថ្ម រួចបានហៅពួកអាភីពួកអាវិន្ត អាវិន្តៗ នោះវាជាប្រធានសន្តិសុខតំបន់៥ ។

ដានី ៈ ឈ្មោះ អី?

សួយៈ ឈ្មោះ វិន្ត ។

ដារ៉ា ៈ ឈ្មោះ វឿន?

សួយៈ បាទ! វឿន ។

ដានី ៈ វឿនហ្នឹងជាប្រធានសន្តិសុខតំបន់៥ ?

សួយៈ បាទ ។

ដានី ៈ វឿនហ្នឹងគាត់នៅណា?

សួយៈ សព្វថ្ងៃខ្ញុំអត់ដឹងទេ ខ្ញុំដឹងតែឈ្មោះវា វាជាប្រធានសន្តិសុខតំបន់៥ ប្រជាជនជាប់គុកមិនថា ទ័ពមិនថាចល័តគឺនៅលើដៃគេ ។

ដារ៉ា ៈ ចឹងមន្ទីរសន្តិសុខតំបន់៥ នៅកន្លែងណា?

សួយៈ ខ្ញុំមិនដែលឃើញកន្លែងសន្តិសុខគេទេ តែខ្ញុំដឹងថាកន្លែងវាយកទៅវៃនៅកន្លែងចំការខ្នុរតែ ប៉ុណ្ណោះឯង កន្លែងទីតាំងវៃណាស់ ។

ដានី ៈ ចំការខ្នុរនៅណាទៅ?

សួយៈ ចំការខ្នុរជើងភ្នំយើងនេះ ជើងភ្នំស្វាយនេះ ។

ដារ៉ា ៈ ជើងភ្នំស្វាយ?

សួយៈ បាទ!សព្វថ្ងៃនេះកើតផ្ទះអស់ហើយ ។

ដានី ៈ ចឹងមន្ទីរសន្តិសុខនៅបន្ទាយនាងអីពូមានដឹងដែរ?

សួយៈ អាមន្ទីរហ្នឹងខាងតំបន់៣ ។

ដានី ៈ អ!ចឹង?

សួយៈ បាទ!បែកគ្នាតំបន់៣ ។

ដានី ៈ ចឹងយ៉ាងម៉េចទៀតទៅពូ?

សួយៈ បានគេចាប់តា ហ៊ីងទៅអស់ទៅបានហៅបងភី ហៅបងភីរួចបានគេចាប់ទ័ពមុន ចាប់ទ័ពដូចថា ហៅលោកប្អូនឯងចេះទៅ ហៅប្អូនឯងឲ្យដកទ័ពមក ឲ្យដកទ័ពមកក៏ដកទ័ពពីខ្សែត្រៀមថៃ យើងទប់គ្នាថៃដកមកក៏ ។

ដានី ៖ បាទ ។

សួយៈ គេឲ្យដាក់កាំភ្លើងដោះកាំភ្លើងឲ្យគេ ឈ្មោះអីៗចេះកាំភ្លើងកាន់ធន់ណាៗ គេឲ្យទៅរៀន ។

ដានី ៖ ចុះតា វ៉ាល់គេចាប់នៅពេលណា?

សួយៈ តា វ៉ាល់ចាប់ដំណាល់គ្នាហ្នឹងពួកតា ញឹម អះ!ដំណាល់តា ភី ។

ដានី ៖ ចាប់ដំណាល់តា ភី តា ហ៊ីង?

សួយៈ បាទ! តា ភី តា ហ៊ីង តា ម៉ោង ។

ដានី ៖ តែពូមានចាប់ខែចាប់ឆ្នាំទេ ពេលគេហៅគេប្រជុំគេចាប់ហ្នឹង?

សួយៈ ខ្ញុំអត់បានចាំឆ្នាំ ខ្ញុំចាប់បានពួកវាឈរជើងនៅមិនដល់មួយឆ្នាំទេ បានត្រូវយួនចូលស្រុក ។

ដានី ៖ អ!ចឹងមកនៅបានមួយឆ្នាំទេ?

សួយៈ បាទ ។

ដារ៉ា ៖ ចឹងវានៅក្នុង៧/៨អីហ្នឹង?

សួយៈ បាទ!បានយួនចូលស្រុក ។

ដានី ៖ ចឹងពូនៅពេលគេចាប់តា ហ៊ីង ចាប់តា ភី ចាប់ តាវ៉ាល់ហើយគេជំនួសមកយ៉ាងម៉េចវិញ ក្នុងភូមិភាគពាយ័ព្យហ្នឹង?

សួយៈ ក្នុងភូមិភាគពាយ័ព្យគេចាប់ពួកហ្នឹងអស់គេថា យើងក្បត់ ។

ដារ៉ា ៖ បាទ ។

សួយៈ ភូមិភាគពាយ័ព្យក្បត់ ។

ដារ៉ា ៖ បាទ ។

សួយៈ ព្រោះភូមិភាគពាយ័ព្យនេះ តាមរបាយការណ៍ដែលខ្ញុំឃើញហ្នឹងភ្នែកគេបោះប្រាក់ ។

ដានី ៖ បាទ ។

សួយៈ រដ្ឋបោះប្រាក់ឲ្យចាយបើកប្រាក់ខែណាស់ ពលទោល២៥រៀល ។

ដារ៉ា ៖ អឺ ។

សួយៈ មានបុណ្យសក្តិបន្តិចបន្តួចទៅ៣០មានបុណ្យសក្តិធំទៅ៥០ប្រាក់ប៉ុល ពតណាស់ ។

ដានី ៖ តែពូខ្ញុំចង់ដឹងថា ពេលគេចាប់តា ញឹម ពីណាគេមកជំនួសតា ញឹម ពូមានដឹងទេត្រង់ហ្នឹង?

សួយៈ អត់មានពីណាជំនួសទេ ។

ដានី ៖ បាទ ។

សួយៈ មានតែតា ម៉ុកគាត់ក្តាប់ ។

ដានី ៖ តា ម៉ុក?

សួយៈ បាទ!តា ម៉ុកក្តាប់ផ្ទាល់ទាំងអស់ ។

ដានី ៖ ចុះតា ហ៊ឹន?

សួយៈ តា ហ៊ឹនជាប់គុកទាំងអស់ ។

ដានី ៖ ចាប់តាហ៊ឹនទៅពីណាមកជំនួសតំបន់៥ ?

សួយៈ ខ្ញុំអត់មានឮឈ្មោះពីណាមកក្តាប់ទេ អត់ដឹងថាពីណាក្តាប់ទេ វាមកដូចថាមកច្របូលច្របល់គ្នាណាស់ ។

ដានី ៖ អឺ ។

សួយៈ សឹងថា យាយ ចែមក្តាប់ក៏ថាបាន ថា តា ម៉ុកក្តាប់ក៏ថាបាន ព្រោះពីរនាក់នេះវាដើរទាំងអស់ ព្រោះស្តាប់ពាក្យតា ម៉ុកទាំងអស់ ។

ដានី ៖ បាទ ។

សួយៈ ហើយតំបន់៥ យើងអត់មានទ័ពអីទេ ។

ដានី ៖ បាទ ។

សួយៈ មានតែតំបន់៥ ឈ្មោះនាមត្រកូលតំបន់៥ តែអត់មានពីណាតំបន់ទេ មានតែពួកខាងគេនិរតីដែលគេមកឈរជើងនៅ តែខ្ញុំមិនបានឃើញមុខគេទេ ។

ដានី ៖ ចឹងមិញមានប្រសាសន៍ថា យាយ ចែមមិញចឹងកាលហ្នឹងពូស្គាល់យាយ ចែម ចឹងយាយចែមគាត់ធ្វើអី គាត់នៅណាដែរ?

សួយៈ យាយ ចែមគាត់ឈរជើងនៅភ្នំត្រយ៉ូងយើងនេះ ។

ដានី ៖ បាទ ។

សួយៈ គាត់ឈរជើងនៅភ្នំត្រយ៉ូងគាត់ធ្វើជាប្រធានសហករណ៍ប្រធានអីចឹងណាស់ តែអំណាចគាត់ធំណាស់ ។

ដានី ៖ អំណាចគាត់ប៉ុណ្ណា?

សួយៈ អំណាចគាត់ដូចម៉ាស្រុកចឹងណាស់ ម៉ាស្រុកព្រះនេត្រព្រះយើងចេះ ។

ដារ៉ា ៖ បាទ ។

សួយៈ អំណាចគាត់ធំ យាយ ថែម ។

ដានី ៖ បើតាមពូស្មានខែណាឆ្នាំណាដែរគាត់មកដល់?

សួយៈ គាត់មកដំណាលគ្នាហ្នឹងពួកនិរតីយើងនេះឯង មកជាមួយគ្នា មកជាមួយគ្នាបានដាក់ពួកយាយ ថែមនៅនេះ ដាក់មី កំផលហ្នឹងឈរជើងនៅឃុំព្រះនេត្រព្រះនេះ ។

ដារ៉ា ៖ បាទ ។

សួយៈ មី កំផលគណៈឃុំ ប្ដីវាឈ្មោះ ផលដែរ ប្ដីវាទ័ព ។

ដារ៉ា ៖ អ៊ី!ចឹងសុទ្ធអ្នកនិរតីដែរ?

សួយៈ បាទ!សុទ្ធតែនិរតីទាំងអស់ ។

ដារ៉ា ៖ ហើយចុះយាយ ថែមហ្នឹងពេលមកដល់បានធ្វើគណៈស្រុកព្រះនេត្រព្រះហ្នឹង យាយ ថែម បានមកចូលរួមមើលឬក៏លើកទំនប់គ្រប់គ្រងអ្នកលើកទំនប់ត្រពាំងថ្មដែលពូ?

សួយៈ អត់ទេ គាត់នៅធ្វើការតែក្នុងនេះ តែគាត់ប្រើកូនចៅរបស់គាត់ណាស់ ។

ដារ៉ា ៖ អឺ ។

សួយៈ កូនចៅគាត់មកពីនិរតីអី គាត់ប្រើ តែខ្ញុំស្ដាប់រៀបរាប់ការណ៍ដែលពួកឈ្លបវានៅជាមួយ យាយ ថែមជាអ្នកដាក់បទបញ្ជាឲ្យវៃឲ្យធ្វើដូចជាគាស់ភ្នំគាស់អី ភ្នំត្រយ៉ូងភ្នំអីណាស់ អាហ្នឹង ជាស្នាដៃរបស់យាយ ថែមគាត់ធ្វើ ។

ដារ៉ា ៖ អឺ ។

សួយៈ បានគាត់រត់ទៅ រត់ទៅតាមផ្លូវភ្នំស្រុកនេះ ។

ដារ៉ា ៖ អឺ ។

សួយៈ គាត់ធ្វើទ័ព គាត់ក្ដាប់ទ័ពម្ដង ។

ដានី ៖ ចឹងអាងត្រពាំងថ្មពីណាទៅគ្រប់គ្រងវិញបន្ទាប់ពីចាប់តា វ៉ាល់តាអីទៅ?

សួយៈ អត់មានពីណាគ្រប់គ្រងទេ អស់ចល័តបែកគ្នា ចល័តមកនៅស្ដានស្រែង មានតែជាងម៉ុង គាត់នៅធ្វើស្ដានមួយក្រុមគាត់ហ្នឹង ។

ដានី ៖ ចឹងនៅតែមួយក្រុមគាត់ហ្នឹងទេ?

សួយៈ បាទ!ធ្វើស្ដានអត់រួច ។

ដានី ៖ អត់រួច?

សួយៈ ធ្វើយួនចូលក៏បែកគ្នា ។

ដារ៉ា ៖ ចឹងស្ដាននៅត្រពាំងថ្មមានពីមែនទេ?

សួយៈ  បាទ ។

ដារ៉ា ៖  ហើយស្ពានទាំងបីហ្នឹងធ្វើអត់រូចទាំងបី?

សួយៈ  អត់រូច ។

ដារ៉ា ៖  ចឹងអត់រូចទាំងបីតែម្ដងពូ?

សួយៈ  បាទ! ព្រោះស្ពាននេះ គាត់ធ្វើដាក់បម្រុងឲ្យឡានធ្វើធំណាស់ ។

ដារ៉ា ៖  បាទ ។

សួយៈ  តា វ៉ាល់ គាត់ថាធ្វើឲ្យធំ ដើម្បីឡានរត់វេសគ្នាបាន ដល់គាត់ធ្វើឲ្យអត់ទាន់សភាពការណ៍និរតីចូលមកវាវុលវិគ្នា ប្រជាជនដើរត់ខ្វះអីខ្វះ ។

ដារ៉ា ៖  បាទ ។

សួយៈ  បើវាកាប់សម្លាប់អត់នេះ ។

ដានី ៖  ចឹងពួកខ្មែរហ្នឹងនៅសល់ក្រុមតា ម៉ុងទេដែលគាត់ធ្វើស្ពានហ្នឹង?

សួយៈ  បាទ ។

ដានី ៖  ចឹងក្រៅពីហ្នឹងចល័តដែលលើកដីអីហ្នឹងអត់មានទេ?

សួយៈ  អត់មានទេ ទៅនៅស្ពានស្រែងអស់ ។

ដារ៉ា ៖  ចុះចល័តសហករណ៍?

សួយៈ  ចល័តសហករណ៍ដកអស់ អត់មានទេ មានតែចល័តម៉ែៗ ចល័តម៉ែៗគ្រាន់តែធ្វើស្រែចំការចេះឯងដកស្ទូងៗតាមសហករណ៍ខ្លួនឯង ។

ដារ៉ា ៖  អឺ ។

សួយៈ  បើចល័តរដ្ឋបើនិយាយទៅបានន័យថា ទៅជាទាហានយើងសព្វថ្ងៃចឹងណាស់ ។

ដារ៉ា ៖  អឺ ។

សួយៈ  បញ្ជូនទៅមុខអស់ មានតែអ្នកក្រោយទេ គេថាអ្នកប្រមូលផលខាងដកស្ទូងក្រោយ ធ្វើស្រែតាមសហករណ៍ ។

ដារ៉ា ៖  មុនហ្នឹងបន្តិចពូបាននិយាយថា ពេលចាប់តា ញឹមហ្នឹងពូបានមើលឯកសារមួយដែលនិយាយពីរឿងចាយលុយ?

សួយៈ  បាទ ។

ដារ៉ា ៖  ហើយថា ទីពឋានៈណាៗប៉ុន្មានរៀលៗហ្នឹងពូនិយាយត្រង់ហ្នឹងឲ្យច្បាស់បន្តិចទេ?

សួយៈ  អាហ្នឹងមិនមែនឯកសារទេ ខ្ញុំឃើញលុយហ្នឹងភ្នែកណាស់ ។

ដារ៉ា ៖ អឺ ។

សួយៈ គ្រាន់តែគ្នាយើងទ័ពដូចគ្នានិយាយណាស់ ។

ដារ៉ា ៖ អឺ ។

សួយៈ និយាយថា ពលទោលហ្នឹងគេបើកបានតែ២៥ទេណាស់ បើគេអ្នកធំគេបាន៣០ទៅ៥០ ។

ដារ៉ា ៖ អឺ ។

សួយៈ ប្រាក់នោះទើបបាត់ វាបាត់យូរគ្រែលហើយ ប្រាក់នោះឃើញនៅក្នុងស្រុកណាស់ ។

ដារ៉ា ៖ បាទ ។

សួយៈ ចេញនៅក្នុងស្រុក ប្រាក់នោះដុតបានចំនួនបានមួយខែបានពុងដំណើងចាប់ភូមិភាគបូព៌ា ។

ដារ៉ា ៖ អ ។

សួយៈ ចាប់ភូមិភាគបូព៌ាមុន ។

ដារ៉ា ៖ អឺ ។

សួយៈ ចាប់ភូមិភាគបូព៌ាតា ញឹមគាត់ដឹងខ្លួនដែរ ដឹងដែលបានប្រាប់តា ហ៊ុងឲ្យប្រមូលទ័ពរត់ចូលព្រៃ
ចេះ ។

ដារ៉ា ៖ អឺ ។

សួយៈ បំរ៉ុងវៃខាងនិរតីវិញ ប្រុងវៃខេត្តតាកែវពីរភូមិភាគនេះវៃខេត្តតាកែវដល់វៃខេត្តតាកែវមិន
ទាន់តា ម៉ុកធ្វើមុន ។

ដារ៉ា ៖ អ ។

សួយៈ តា ម៉ុកគាត់កាច់បានមុនក៏ចាប់តា ញឹមបានយកទៅប្រជុំ ។

ដារ៉ា ៖ ចឹងបានន័យថាលុយហ្នឹងបាបចរាចរណ៍មកដល់ភ្នំស្រុកហើយចឹង?

សួយៈ បាទ ។

ដារ៉ា ៖ ចឹងពូមានបានឃើញលុយហ្នឹងដែរ?

សួយៈ បាទ!បានឃើញលុយ លុយហ្នឹងសញ្ញារូបគោយើងហ្នឹង មានន័ង្គ័លភ្ជួរ ។

ដានី ៖ លុយលន់ នល់ទេ រូបគោភ្ជួរ?

សួយៈ មិនលុយពីដើមមិញទេ លុយនោះពណ៌វាទង់ដែងណាស់ ពណ៌ទង់ដែងក្រដាសវាតូចប៉ុននេះ ។

ដារ៉ា ៖ តែក្នុងហ្នឹងគេដាក់អក្សរយ៉ាងម៉េច?

សួយៈ គោ ។

ដារ៉ា ៖ តែអក្សរយើងសរសេរហ្នឹងណាស់ ដាក់ថា លន់ នល់ឬកម្មុជាប្រជាធិបតេយ្យឬក៏យ៉ាងម៉េច ?

សួយៈ អក្សរខ្ញុំមិនបានពិចារណាអក្សរទេ ខ្ញុំគ្រាន់តែមើលតែរូបឃើញយើងដូតក្បាលកន្ទ្រេងចេះ ។

ដារ៉ា ៖ អឺ ។

សួយៈ ដូតក្បាលកន្ទ្រេងចេះកាន់ដំបងចេះគោមួយនឹម ។

ដារ៉ា ៖ អ!អាហ្នឹងរកដាសប៉ុន្មានពូ?

សួយៈ អាហ្នឹងក្រដាស១០បាត អះជ្រាស១០០អះក្រដាស១០រៀលយើងណាស់ ។

ដារ៉ា ៖ ក្រដាស១០រៀល?

សួយៈ បាទ ។

ដារ៉ា ៖ ជាប់មាត់១០បាត១០បាតរហូត?

សួយៈ បាទ ។

ដានី ៖ ចឹងពូពេលពូដកចេញពីទំនប់មកកន្លែងកូនក្លែងវិញហ្នឹង អាហ្នឹងពួកនិរតីគេមកហើយ?

សួយៈ បាទ!មកហើយ គេមកតាម ។

ដារ៉ា ៖ អឺ ។

សួយៈ ពួកនិរតីមកក៏អត់ដឹងថាពួកខ្ញុំនៅក្នុងព្រៃ ។

ដារ៉ា ៖ ចឹងអត់ដឹងទេ?

សួយៈ អត់ដឹងទេ ចាប់អស់ចាប់ម៉ាតំបន់៥នេះអស់រលីង នៅសល់ពួកខ្ញុំ១០០នាក់ប៉ុណ្ណោះឯង ។

ដារ៉ា ៖ នៅក្នុងព្រៃហ្នឹង?

សួយៈ នៅក្នុងព្រៃ ។

ដានី ៖ ចឹងនៅក្នុងព្រៃកូនក្លែងហ្នឹង?

សួយៈ នៅព្រៃកូនក្លែងនៅតាមខ្សែត្រៀម ។

ដារ៉ា ៖ អឺ ។

សួយៈ គ្រាប់ម្នាក់មួយគ្រាប់ពីរគ្រាប់កាំភ្លើង ។

ដារ៉ា ៖ អស់ហើយ?

សួយៈ អស់ហើយបានចំនួនជិតកន្លះខែបានវាដឹង វាដឹងគេផ្ញើនិរសាទៅឲ្យពួកខ្ញុំ គេដាក់ថាដល់ទាំងយប់ឲ្យមកយកទាំងយប់ដល់ថ្ងៃឲ្យដល់ទាំងថ្ងៃ ហើយក៏ប្រធានកងតូចខ្ញុំ ។

ដារ៉ា ៖ ឈ្មោះអីប្រធានកងតូចពូ?

សួយៈ ប្រធានកងតូចខ្ញុំឈ្មោះ តា អាត ។

ដារ៉ា ៈ អ!តា អាត?

សួយៈ តា អាត តា អាតគាត់មើលគាត់ថាគេហៅឡើងទៅលើហើយ មិត្តអើយរៀបចំឥវ៉ាន់គេហៅឡើងទៅភ្នំស្រុកម៉ោង១២យប់ ទឹកត្រឹមនេះអាត្រពាំងថ្មនេះទឹកឡើងគគើម ។

ដារ៉ា ៈ ត្រឹមក?

សួយៈ បាទ!ត្រឹមកនាំគ្នាដើរមក ដើរមកដល់អាងត្រពាំងថ្មនេះភ្លឺដល់អាងត្រពាំងថ្មនេះដល់វត្តត្រពាំងថ្មនេះភ្លឺ ។

ដារ៉ា ៈ បាទ ។

សួយៈ ដើរពីត្រពាំងថ្មមកដល់ភ្នំស្រុក មកដល់ភ្នាមឃើញនិរតីអន្លុយរីកអន្លុយ៥នាក់ អាវគេខៀវខោខៀវ មិត្តឯងមានគ្រាប់ប៉ុន្មានគ្រាប់ ខ្ញុំដើរមុនគេខ្ញុំថាសល់គ្រាប់ពីរគ្រាប់ ចុះគ្រាប់បែកគ្រាប់បែកបីគ្រាប់ កាំភ្លើងគេដាក់ធុនអី អុនអាកាចេះ ។

ដារ៉ា ៈ អឺ ។

សួយៈ ធុនអាកាទុកកាំភ្លើងត្រង់នេះ ចុះៗរួចគេថាមិត្តឯងទៅមុជទឹកក៏សុំច្បាប់ទៅបត់ជើងទៅសុំច្បាប់ទៀត ។

ដារ៉ា ៈ អឺ ។

សួយៈ ខ្ញុំថា អីយ៉ាយើងកុនហើយប៉ុននេះហើយមិនបានរស់ទេ ជាប់គុកហើយយើង គេយកយើងទៅវ៉ៃចោលហើយ នៅជាមួយគេបាន១០ថ្ងៃ នៅបាន១០ថ្ងៃដូចបានលោកជួយប៉ារាំនេះចូលនេះចូលស្រុក ។

ដារ៉ា ៈ ប៉ារាំ?

សួយៈ ពួកប៉ារាំយើង ។

ដារ៉ា ៈ ពួកទាហានប៉ារាំហ្នឹង?

សួយៈ បាទ!ទាហានប៉ារាំ កុយ ឈា យើងនេះណាស់ ។

ដានី ៈ យ៉ាងម៉េចខ្ញុំដូចជាអត់យល់?

សួយៈ កុយ ឈានៅថ្មពួករាល់ថ្ងៃនេះ ។

ដារ៉ា ៈ គាត់ឈ្មោះ កុយ ឈា?

សួយៈ បាទ!ពីដើមមិញគាត់ជាប្រធានកងពលលេខ៧កាលពីដើមមិញណាស់ កុយ ឈា ឡាច ខែចហ្នឹង ។

ដានី ៖ សឺន សានហ៊្វីន ខាងប៉ារាសី សានហ៊្វីនឬមិនមែនទេ?

សួយៈ ទេ ខាងសឺន សានហ៊្វីនឯង ។

ដារ៉ា ៖ យ៉ាងម៉េចបានជាពាក់ព័ន្ធមកនេះវិញ?

សួយៈ ទេ អានេះគាត់ចូលមកលេងប្រពន្ធគាត់ ដូចថារត់ចូលដីថៃហើយគាត់លបចូលមកប្រពន្ធ ។

ដារ៉ា ៖ អ ៗ ។

សួយៈ លបចូលមកប្រពន្ធប្រជាជនរាយការណ៍ថា ប៉ារាចូលស្រុកបានខាងនិរតីនេះរៀបចំឲ្យខ្ញុំកាន់ប្រធានក្រុម ។

ដារ៉ា ៖ អឺ ។

សួយៈ គេឲ្យកាំភ្លើងខ្ញុំថាប៉ុននេះខ្ញុំរស់ហើយអញ លើកនេះប្រាប់គ្នាខ្ញុំថាបើវារករឿងយើងបាញ់វារត់ចូលព្រៃ ។

ដារ៉ា ៖ អឺ ។

សួយៈ ពួកពាយ័ព្យស្តាប់ខ្ញុំទាំងអស់ ខ្ញុំនៅនេះដូចជាមេកងធំគេហើយ ។

ដារ៉ា ៖ អឺ ។

សួយៈ ខ្ញុំនាំនិរតី និរតីទៅតែពីរនាក់ទេ ទៅតែពីរនាក់វាតាមដានពួកខ្ញុំណាស់ពួកវាទៅពីរនាក់អត់ឲ្យធ្វើប្រធានទេ ។

ដារ៉ា ៖ អឺ ។

សួយៈ ឲ្យធ្វើវេងខ្ញុំ ខ្ញុំក៏ទៅហៅអំពិលកងណាំតាវយើងនេះណាស់ អាដួវអាងត្រពាំងថ្មយើងនេះ ។

ដារ៉ា ៖ អឺ ។

សួយៈ នៅនោះឯងនៅក៏ កុយ ឈាចេញផុត ចេញផុតពួកខ្ញុំឈរជើងនៅនោះកន្លែងខ្ញុំអាសល់នៅភ្នំពេញភ្នំនេះឯងវាទាស់គ្នា ។

ដារ៉ា ៖ ពីណាគេតូ?

សួយៈ អា សល់ ។

ដារ៉ា ៖ ឈ្មោះ សល់?

សួយៈ បាទ ។

ដានី ៖ ចឹងសព្វថ្ងៃគាត់នៅភ្នំពេញ?

សួយៈ	គេធ្វើការនៅភ្នំពេញ អាសល់គេទាល់គ្នាគេថា អានិរតីក្បត់ពួកឯងជ្រាំតែបបរទេថា ដល់នេះខ្ញុំថានេះ កំភ្លើប្រយ័ត្នវាវាយការណ៍វៃផាប់ ដល់នេះពួកនិរតីថាពួកអាពាយ័ព្យសុទ្ធពួកអាក្បត់ ។

ដារ៉ា ៈ	អឺ ។

សួយៈ	រត់ចូលព្រៃមួយពីរៗបានខ្ញុំថា មិត្តអើយមិនបាច់និយាយទេ មិត្ត មិត្តគ្នាយើងតើទៅទាស់អីគ្នា ។

ដារ៉ា ៈ	អឺ ។

សួយៈ	១០ថ្ងៃវាវាយការណ៍ដកពួកខ្ញុំមក ។

ដារ៉ា ៈ	ដកមកវិញ?

សួយៈ	បាទ!ដកមកឲ្យសែងអាចម៍ ខ្ញុំដល់កខ្ញុំ ខ្ញុំក៏ឲ្យពួកកូនចៅខ្ញុំផង ណែសែងអាចម៍គ្នាពីរនាក់ ចុះអាចម៍ចល័តនិយាយស្នាទោស មានលឿងមានខ្មៅស្អីសព្វមុខចុះមានអីស៊ី ខ្ញុំក៏សែងៗយើងមិនដែលដឹង អាសែងស្រស់ញញឹមដល់នេះបានចល័តប្រជាជនថ្មីយើងប្រាប់ថា មិត្តកូនអើយបើមិត្តកូនចង់បាត់ស្អុយយកដេះ បានខ្ញុំប្រាប់ថាយកដេះចាក់ទៅដល់ចាក់ដេះអត់មានស្អុយទេ ដល់យើងដាក់ជាប់ស្នាចេះក៏មិនអី ដល់សែងៗទៅស្នាទោសបិុសស៊ីអាចម៍ទៀត ឲ្យសែងអាចម៍រួចបានកន្ទះខែវាឲ្យរើសអាចគោមួយថ្ងៃឲ្យបានពីការ៉ុង ទៅរើសអាចគោណាបានបើវាកណ្ដាលវា ។

ដារ៉ា ៈ	អឺ ។

សួយៈ	បើប្រជាជនវារើសមុនឯងអស់ នៅហ្នឹងឲ្យស៊ីមួយថ្ងៃមួយកំប៉ុង ។

ដារ៉ា ៈ	អឺ ។

សួយៈ	ពួកខ្ញុំក៏មិនលាន់មួយថ្ងៃមួយកំប៉ុងៗ ។

ដារ៉ា ៈ	អឺ ។

សួយៈ	ដល់ហើយបានចាប់ប្រធានកងធំខ្ញុំ ។

ដារ៉ា ៈ	ឈ្មោះ អីប្រធានកងធំ?

សួយៈ	ឈ្មោះ តា ណាក ។

ដារ៉ា ៈ	តា ណាក?

សួយៈ	បាទ!ដល់នេះខ្ញុំប្រាប់បង បងឯងប្រុសណានេះចាប់តា ហាត់គណៈស្រុកហើយ តា ហាត់គណៈស្រុកភ្នំស្រុក ។

ដារ៉ា ៖ បាទ!មានបងឈ្មោះ តា ម៉ន?

សួយៈ បាទ!តា ហាត់គណៈស្រុក ។

ដារ៉ា ៖ បាទ ។

សួយៈ ចាប់ តា ហាត់ថ្ងៃនេះស្អែកឡើងហៅគាត់ ខ្ញុំថាបងប្រុនណាស់ចាប់តា ហាត់ហើយបើបងឯង ចូលទៅសភាពការណ៍មិនស្រួលហើយឆាប់រត់មកដល់ខ្ញុំវិញមក ព្រោះពួកខ្ញុំមានកាំភ្លើងហើយ ម៉េចៗរត់ចូលព្រៃទាំងអស់គ្នាទៅ គាត់គេហៅទៅប្រជុំគាត់អង្គុយកៅអីចេះហើយ អង្គុយ និយាយចុះឡើងៗនិយាយពាក្យល្អទេ គេចាប់យើងហ្នឹង ។

ដារ៉ា ៖ អឺ ។

សួយៈ និរតីអត់មានពិបាកផ្លូវពិបាកអីទេ ហៅមកអង្គុយនិយាយលេងនិយាយលេងក៏ឲ្យឡើងផ្ទះថ្ម នៅលើចាប់ក្រឹបដាក់ឡានបញ្ជូនមកគេហៅកន្លែងលាក់ការណ៍ៗ កន្លែងលាក់ការណ៍ស្វាយ ណាស់ ។

ដារ៉ា ៖ អឺ ។

សួយៈ កន្លែងប៉ូលីសលោកឡូញណាស់ លោកមា អាកន្លែងលោកឡូញនៅហ្នឹងណាស់ កន្លែងលោក ឡូញនៅចាស់ ។

ដារ៉ា ៖ អឺ ។

សួយៈ គេចាប់ដាក់គុកនោះហើយ ពួកខ្ញុំក៏អស់សង្ឃឹមដល់វេនអញហើយ ព្រោះគេបញ្ជូនមកកកោះ នេះឿយណាស់ ឲ្យស៊ីមួយថ្ងៃកន្ទះកំប៉ុង ពួកខ្ញុំក៏ពិគ្រោះគ្នាថា ពួកយើងយ៉ាងម៉េចៗរត់ចូល ព្រៃទៅ រត់ទៅថៃដល់ពេលនេះក៏នៅៗទៅ គេរើសគេបញ្ជូនមកតំបន់៣យើងនេះ ។

ដារ៉ា ៖ អឺ ។

សួយៈ មកតំបន់៣នៅតំបន់៣វ៉ៃម៉ាខ្មៅនេះហើយ វ៉ៃម៉ាខ្មៅគ្រាំៗខ្ញុំយកគ្រាប់កាំភ្លើងបានល្អក៏ដាក់ ចេះទៅ ដាក់ចេះបាញ់ខ្លួនឯងបាញ់យ៉ាងម៉េចឲ្យគ្រាប់កាំភ្លើងត្រូវភ្លៅអញ ស្ទាបមើលបើត្រូវ សាច់ត្រូវចុះកុំឲ្យត្រូវឆ្អឹងបាក់ ខ្វាចកំបុតដាក់កាំភ្លើងចេះដូចវាអត់មុតក៏ប៉ោងអាសាច់នេះ ប៉ោងសាច់អត់មុតខ្ញុំថា អីយ៉ាងធ្វើម៉េចបានរបួសទេអញ អត់បាយបីថ្ងៃ អត់ស៊ីបាយទេ គេ សួរថាមិត្តឯងស្អី ខ្ញុំថាខ្ញុំគ្រុនគេលើកបាយមកឲ្យក៏ខ្ញុំមិនស៊ី ខ្ញុំឃ្លានតែអត់ស៊ីទេ ស៊ូមិនបានខ្ញុំ រត់ហើយខ្ញុំរត់នឹកប្រពន្ធផង រត់សេនាជនតាមបាញ់ខ្ញុំ រត់មកនៅស្រុកប្រពន្ធ ។

ដារ៉ា ៖ នៅស្រុកអីហ្នឹង?

សួយៈ នៅស្រុកពោធិវង្ស ។

ដារ៉ា ៖ អឺ ។

សួយៈ ប្រពន្ធខ្ញុំចេញពីពេទ្យគេដកអ្នកមានគ្រួសារខាងនិរតីគេដកចេញអស់ មិនថាបុណ្យសក្តិប៉ុណ្ណាទេ គេដកចេញខ្ញុំក៏មកនៅបានយួនចូលស្រុករត់ចូលទាហានយួន ។

ដានី ៖ ចឹងពូរៀបការនៅឆ្នាំណា?

សួយៈ ខ្ញុំការនៅពាក់កណ្តាលឆ្នាំ៧៧ ។

ដារ៉ា ៖ ធ្វើម៉េចបានការ?

សួយៈ អង្គការគេបើកឲ្យ ឲ្យក៏យើងស្ទើរអត់មានបានឃើញមុខគ្នាទេ ឲ្យស្គាល់តែឈ្មោះបានហើយ ។

ដារ៉ា ៖ អឺ ។

សួយៈ ជួនកាលយើងមើលដៃមើលជើងគេមិនទាន់កំបុត្រក៏មាន ស្រីបានប្តីកំបុតក៏មាន ។

ដានី ៖ កាលហ្នឹងឆ្នាំ៧៧ហ្នឹង អង្គការរៀបចំផ្សំផ្គុំឲ្យពូប្តូក៏ពូមើលឃើញមីងហើយបានរៀបការ?

សួយៈ ទេ ខ្ញុំមើលឃើញគេឲ្យស្ទើ គេឲ្យស្ទើគ្រួសារខ្ញុំក៏ស្គាល់មនុស្សឲ្យកំប៉ិះ ។

ដានី ៖ បាទ ។

សួយៈ ខ្ញុំមិនដឹងជាស្ទើពីណាទេ ។

ដារ៉ា ៖ អឺ ។

សួយៈ ខ្ញុំក៏សាកមើលថា ក្តីខ្ញុំអាសល់នេះហើយថា ស្ទើប្រពន្ធទៅអា ខ្ញុំថាមិនដឹងជាស្ទើពីណាទេ យ៉ាស្ទើពេទ្យរ៉េតទៅវាប្រធានពេទ្យបើវាមិនយកហ៊ី សាកមើលវាទៅយើង ។

ដារ៉ា ៖ អឺ ។

សួយៈ អាសល់នៅកន្លែងខ្ញុំនោះដាក់ឈ្មោះ ពេទ្យ ។

ដារ៉ា ៖ បាទ ។

សួយៈ ស្ទើពេទ្យស្រុក ស្ទើទៅមិនដឹងថាបានមិនដឹងថាអីទេ ដល់នេះអង្គការហៅខ្ញុំឡើងមកគេថាដល់ ទាំងយប់ឲ្យមកទាំងយប់ខ្ញុំថាងាប់បាត់ហើយចុះ មកប្រើខ្ញុំឲ្យទៅដឹកគោដឹកអីគេប្រាប់ថាការ ចាប់ដៃគ្នា ។

ដានី ៖ ចឹងកាលហ្នឹងប្រពន្ធពូគាត់ធ្វើប្រធានពេទ្យស្រុកថ្នាក់?

សួយៈ ស្រុកភ្នំស្រុក ។

ដានី ៖ ស្រុកភ្នំស្រុក?

សួយៈ បាទ ។

ដានី ៖ គាត់ធ្វើប្រធានពេទ្យតាំងពីកាល?

សួយៈ ធ្វើតាំងពីឆ្នាំ៧០ប៉ុន្មានទេ ខ្ញុំមិនសូវស្គាល់ជីវប្រវត្តិគេអស់ទេ ។

ដារ៉ា ៖ អ ។

សួយៈ គេនៅខាងជីវំដោះណា ។

ដានី ៖ បាទ!ដល់ពេលការហើយពូនៅជាមួយគ្នាឬអត់ទេ?

សួយៈ ការបានពីរយប់បានគេបញ្ជូនខ្ញុំឲ្យទៅនៅកូនក្អែងវិញ ។

ដានី ៖ ទៅកូនក្អែងវិញ?

សួយៈ បាទ! បានបកពីកូនក្អែងបានឲ្យខ្ញុំមកនៅអាងត្រពាំងថ្មវិញ វាត្រឡប់ត្រឡិន ។

ដារ៉ា ៖ ចឹងអត់មាននៅជាមួយគ្នាទេចុះ?

សួយៈ ទេ ដកទៅដកមកពួកខ្ញុំដកទៅដកមកនៅអាងត្រពាំងថ្មនេះឯង នៅកូនក្អែងផងនៅអាងត្រពាំងថ្មនេះផង ។

ដានី ៖ ចុះពូថាខាងនិរតីចាប់ពូទៅសម្ងាប់ហើយពូវ៉ៃតបវិញហ្នឹងឆ្នាំណាហ្នឹង?

សួយៈ អាហ្នឹងដែលខ្ញុំការប្រពន្ធរួចហ្នឹង ខ្ញុំប្រពន្ធខ្ញុំចាំមិនបានទេ កាលនោះប្រពន្ធអ្នកមើលខ្ញុំហ្នឹងហើយខ្ញុំ ខ្ញុំគេវ៉ៃហើមដៃហ្នឹង ខ្ញុំភ្លេចអាឆ្នាំដែលនិរតីវ៉ៃ ។

ដានី ៖ ៧៨ហើយទេ?

សួយៈ បាទ ។

ដារ៉ា ៖ ៧៨ឬ៧៧ ចុង៧៧ឬក៏ដើម៧៨?

សួយៈ ប្រហែលជាចុងឆ្នាំ បើមិនចុងឆ្នាំទេ ៧៨ហើយ ។

ដានី ៖ បាទ ។

សួយៈ ព្រោះនិរតីដឹកមកវាច្រើនឈ្មោះ មី កំដល ឈ្មោះ មី ក្រង៉ែតណាស់ ។

ដារ៉ា ៖ បាទ ។

សួយៈ មី កាង៉ែតជាឈរជើងនៅជីតា ប៉ែននោះ ។

ដារ៉ា ៖ អឺ ។

សួយៈ មីកាង៉ែតហ្នឹងកាច ។

ដារ៉ា ៖ ចឹងចូលមកដល់ក្នុងភូមិពូមានស្គាល់ពួកនិរតីនៅក្នុងភូមិពូមានស្គាល់ពីណាខ្លះពូសាកនិយាយមើលឈ្មោះមើលមានប៉ុន្មាននាក់?

សួយៈ ខ្ញុំស្គាល់ដែលខ្ញុំស្គាល់ផ្ទុំដើរហ្នឹងខ្ញុំវាច្រឡឹមហ្នឹងស្រីៗ ។

ដារ៉ា ៖ អឺ ។

សួយៈ ខ្ញុំខូចហ្នឹងស្រីៗ បើសម័យហ្នឹងគេថាប្រពន្ធច្រើន ។

ដារ៉ា ៈ បាទ ។

សួយៈ ខ្ញុំសម័យកាលនោះខ្ញុំកំលោះខ្ញុំចេះតែមាត់ខ្ញុំវារប៉ូចចេះៗ ។

ដារ៉ា ៈ បាទ ។

សួយៈ ចេះៗស្គាល់គេមីកាវ៉ែតមកពីនិរតីនៅគា ប៉ែនឈ្មោះ មី កំដន អុសមី កំភន មិត្តខនអា នោះម៉ែឪវានៅហ្នឹងយើង ។

ដារ៉ា ៈ អឺ ។

សួយៈ ពេលខ្ញុំមកខ្ញុំទៅលេងហ្នឹងគេ ស្គាល់គេខ្ញុំឈរជើងនៅភ្នំស្រុកណាស់ ។

ដារ៉ា ៈ បាទ ។

សួយៈ ពេលហ្នឹងខ្ញុំសុំច្បាប់គេមកលេងហ្នឹងម៉ែ ចេះតែស្គាល់បើមីកំដលនេះគណៈឃុំនេះប្ដីវានៅទ័ព នៅនិរតីនេះ ។

ដារ៉ា ៈ បាទ ។

សួយៈ មេវាអាប៊ុរៀមៗ ។

ដានី ៈ អ!ពូស្គាល់ប៊ុរៀមដែរ?

សួយៈ ស្គាល់ ។

ដានី ៈ ប៊ុរៀមគាត់ធ្វើអី?

សួយៈ ប៊ុរៀមគាត់គេហៅប្រធានវរៈ ។

ដានី ៈ ប្រធានវរៈ?

សួយៈ បាទ!ប្រធានវរៈ២០២ ។

ដានី ៈ ចឹងប្រធានវរៈ២០២?

សួយៈ បាទ!ភាគ ។

ដានី ៈ របស់ភាគ?

សួយៈ ភាគនិរតី២០២ ។

ដារ៉ា ៈ ទ័ពភូមិភាគ?

សួយៈ បាទ!ទ័ពភាគ ហៅទ័ពភូមិភាគក៏បានតែគេហៅទ័ពភាគ ។

ដានី ៈ គាត់ឈរជើងនៅណាគា រៀម?

សួយៈ គាត់ឈរជើងនៅដុប ។

ដានី ៖ គាត់ឈរជើងនៅជប់ហ្នឹង?

សួយៈ បាទ!តែទាហានយើងដាក់ពីនេះទៅដល់បាត់ដំបង ។

ដានី ៖ ឈ្មោះ តា វៀមប្រពន្ធគាត់ឈ្មោះអី?

សួយៈ ខ្ញុំអត់ស្គាល់ប្រពន្ធគាត់ទេ ស្គាល់តែគាត់ដែលគាត់នៅនេះណាស់ ។

ដារ៉ា ៖ រូបរាងគាត់យ៉ាងម៉េច?

សួយៈ គាត់ស្តើងខ្ពស់ ។

ដានី ៖ ហើយក្រោមមកតា វៀមនៅណាវិញ?

សួយៈ សម័យរត់ចូលមកតា វៀមគាត់រត់ចូលព្រៃ រត់ចូលព្រៃទ័ពគាត់ឡើងមកចូលព្រៃមាន់នេះ ។

ដានី ៖ គាត់មានទៅធ្វើគណៈស្រុកនៅថ្មពួកទេ?

សួយៈ ខ្ញុំកាលនោះខ្ញុំទៅអត់ដល់ទេ ខ្ញុំដឹងមិនដល់ ។

ដានី ៖ បាទ ។

សួយៈ ដឹងថាគាត់នៅជាប់យើងនេះ ដូចថាគាត់រត់ទៅនោះហើយ ។

ដានី ៖ បាទ ។

ប្រុញៈ អត់ទោសពូសុំសួរថយក្រោយបន្តិច ពូថាកាលតា ម៉ុកមកហ្នឹង ចោទថាខាងភូមិភាគពាយ័ព្យសម្លាប់ពួកចិនពូ?

សួយៈ ថា ម៉េច ។

ដារ៉ា ៖ ចេះពូដូចពូនិយាយថា គេចាប់តា ញឹម ចាប់អីហ្នឹង ដោយសារតា ម៉ុកចោទថា ភូមិភាគពាយ័ព្យហ្នឹងតា ញឹមហ្នឹងឯងអ្នកសម្លាប់ទូតចិន?

សួយៈ បាទ ។

ប្រុញ ៖ មានការសម្លាប់ចិនមែនដែលអត់ពូ?

សួយៈ អត់ទេ អត់បានសម្លាប់ទេ តា ញឹមគាត់អត់ដឹងទេ តា ញឹមគាត់បំរ៉ុងប្រែសន្តម ។

ដារ៉ា ៖ អឺ ។

សួយៈ ឲ្យប្រជាជនលក់របស់របរក្នុងសហករណ៍យើងណាស់ មានការទិញដូរគ្នាបានគេបោះប្រាក់ ។

ដារ៉ា ៖ អឺ ។

សួយៈ បោះប្រាក់នោះដើម្បីបើកឲ្យប្រជាជនទិញឥវ៉ាន់សហករណ៍ ។

ដារ៉ា ៖ អឺ ។

សួយៈ ចេះដល់ភូមិភាគបូព៌ា ។

ដារ៉ា ៖ អឺ ។

សួយៈ ដល់ពេលនេះគេបានចាប់ភូមិភាគបូព៌ានេះ បានមានខ្មែរបណ្តាញមកដល់តា ញឹមនេះ ។

ដារ៉ា ៖ អឺ ។

សួយៈ ប៉ុនបើរឿងភូមិភាគពាយ័ព្យអត់មានទេ ។

ដារ៉ា ៖ ចឹងពេលដែលចាប់ទៅការមិននិយាយរឿងការចាយលុយអីទេ?

សួយៈ អត់ទេ ។

ដារ៉ា ៖ គេយកហេតុផលរឿងបាញ់ទូតចិន?

សួយៈ បាទ ។

ដារ៉ា ៖ តែតាមពូស្មានមើលថា តើព្រឹត្តិការនៃការបាញ់ទូចចិននោះវាមានមែនឬមួយយ៉ាងម៉េច?

សួយៈ បាញ់កាលទូតចិននេះមានមែនភូមិភាគបូព៌ាបាញ់ ។

ដារ៉ា ៖ បាញ់មែន?

សួយៈ បាទ! បាញ់មែនភូមិភាគបូព៌ា បាញ់បានភូមិភាគបូព៌ានិងភូមិភាគពាយ័ព្យនេះវាចំណងមិត្តភាពគ្នាណាស់ ។

ដារ៉ា ៖ អ! បាទ ។

សួយៈ វាត្រូវគ្នាដល់តា ម៉ុកនិងភូមិពាយ័ព្យបូព៌ាអត់ដែលត្រូវគ្នាទេ ដណ្តើមគ្នាធ្វើធំ ។

ដារ៉ា ៖ បាទ ។

សួយៈ បានពួកតា ម៉ុកដាញ់ភូមិភាគពាយ័ព្យនិងភូមិភាគបូព៌ា ។

ដារ៉ា ៖ ចឹងអាយុហ្នឹងបានមកពីណាចុះ?

សួយៈ លុយនោះខ្ញុំអត់ដឹង ប៉ុនគ្រាន់តែមេខ្ញុំប្រាប់យកលុយមកបង្ហាញយើងថា គេបំរុងបើលុយឲ្យចាយគ្រាន់តែលុយនេះយើងមើលឃើញថា កន្សែងជូតក្បាលកាន់ថៅងក្ករដើននង្គ័លយើងលុយនោះពណ៌ក្រហម ។

ដារ៉ា ៖ បាទ ។

សួយៈ អាក្រហមទង់ដែងយើង ពណ៌រាងសាច់ឈើនេះ ។

ដារ៉ា ៖ ឃើញប៉ុន្មានសន្លឹក?

សួយៈ គេយកមកបីសន្លឹក ។

ដារ៉ា ៖ បីសន្លឹកក្រដាស១០រៀលទាំងបីឬមួយយ៉ាងម៉េច?

សួយៈ ក្រដាស១០មួយក្រដាស២០មួយ អះ!ក្រដាស២០ពីរសន្លឹក គ្រាន់គេប្រាប់ថាពេលទោយើងបាន២០ ។

ដារ៉ា ៖ អឺ!ចឹងពូត្រូវបានប៉ុន្មាននៅពេលគេដដែកគ្នាហ្នឹង?

សួយៈ ខ្ញុំបាន២០បាត ។

ដារ៉ា ៖ ២០រៀល?

សួយៈ បាទ ។

ប្រុញ ៖ ពូកាលដែលថា បាញ់ទូតចិនហ្នឹងពត៌មានដឹងដល់គណៈមជ្ឈិមទេ?

សួយៈ អានេះពត៌មានដែលបាញ់ទូតចិននេះ គ្នាឯងនិយាយមកពីលើៗមកណាស់ ។

ដារ៉ា ៖ ចឹងនិយាយតៗគ្នាមក?

សួយៈ បាទ!និយាយតគ្នាមក គេថាភូមិភាគពាយ័ព្យនេះបាញ់ទូតចិន ដល់ស៊ើបអង្កេតតាមដានទៅគ្នាយើងដឹងថាភូមិភាគនិរតី អះ!ភូមិភាគបូព៌ាបាញ់ទូចចិនស្លាប់មែន ។

ដារ៉ា ៖ អ ។

សួយៈ រឿងវាមានចំណងប៉ះពាល់គ្នានិងភូមិភាគបូព៌ានិងទូតចិននេះវាមានប៉ះពាល់គ្នាពីរឿងសកម្មភាពអ្វីមួយដោយសារតា ម៉ុក ។

ដារ៉ា ៖ ចឹង?

សួយៈ បាទ!បាញ់ទូតចិននេះដើម្បីកុំឲ្យតា ម៉ុកត្រូវគ្នាជាមួយទូតចិន ។

ដារ៉ា ៖ អ ។

សួយៈ ព្រោះទូតចិននេះតា ម៉ុកបំរ៉ុងរៀបចំសម្លាប់ប្រុសៗឲ្យអស់ដើម្បីយកស្រីៗបង្កាត់ចិន ។

ដារ៉ា ៖ ចឹងរឿងចឹងមានចឹងមែនទេពូ?

សួយៈ គេប្រុងធ្វើចេះឯងបាននិរតីវាមកនេះវាប្រុងវៃប្រុសៗដើរតាមខ្សែបណ្តាញរបស់តា ម៉ុក ។

ដានី ៖ ចឹងពូមានប្រសាសន៍មិញថា តា ម៉ុកប្រុងសម្លាប់ប្រុសៗឲ្យអស់យកស្រីៗមកបង្កាត់ជាមួយចិន យកស្រីខ្មែរយើងបង្កាត់ជាមួយចិនហ្នឹង ពូឮពត៌មានហ្នឹងឮតាមណាមក?

សួយៈ អានេះឮតាមម៉ីគ្នាយើង ម៉ីយើងប្រាប់មកណាស់ ។

ដានី ៖ អ!មេៗរបស់ពូ?

សួយៈ បាទ ។

ដានី ៖ មេៗណាខ្លះមេថ្នាក់ណាប្រាប់ហ្នឹង?

សួយៈ តា ណាកអឺគាត់ប្រជុំទ័ពខាងគណៈស្រុកខាងមេទ័ពយើងហ្នឹងណាស់ ។

ដារ៉ា ៖ អ ។

សួយៈ និយាយប្រាប់ទ័ព ហើយបានឲ្យភូមិភាគពាយ័ព្យនេះប្រុង ។

ដារ៉ា ៖ អឺ ។

សួយៈ កុំឲ្យចាញ់និរតី ដល់ប្រុងបានដឹកគាំភ្លើងចូលព្រៃអស់ ដល់ពេលគេហៅដឹកចូលព្រៃ អស់ពីចូលមកវិញគេចាប់ស្រួលនៅផ្ទះ គេហៅតា ម៉ុក ។

ដារ៉ា ៖ ចឹងមានន័យថាខាងបូព៌ាហ្នឹងធ្វើសកម្មភាពមុន?

សួយៈ បាទ ។

ដារ៉ា ៖ បាញ់ទូតចិនហ្នឹងកុំឲ្យទូតចិនហ្នឹងត្រូវជាមួយតា ម៉ុកខ្លាំង?

សួយៈ បាទ ។

ដារ៉ា ៖ ចង់សំដៅនិយាយចឹងពូ?

សួយៈ បាទ! ព្រោះភូមិភាគបូព៌ានេះវាបំរុងរត់ចូលព្រៃ ចូលមកនៅពាយ័ព្យ ។

ដារ៉ា ៖ អ ។

សួយៈ ចំណងមិត្តភាពពីរភូមិភាគនេះវិនិរតីសង្គ្រប់ឲ្យរលាយដើម្បីរៀបចំបដិវត្តនេះ ស្អីណាគេរៀបឲ្យមានសហករណ៍លក់ដូរឥវ៉ាន់ ។

ដារ៉ា ៖ អឺ ។

សួយៈ ដើម្បីឲ្យប្រជាជនពិបាកទៅទិញអីណាអីណីណាស់ ។

ដារ៉ា ៖ បាទ ។

សួយៈ តា ញឹមគាត់ប្រុងធ្វើចុះឯង ដើម្បីបានប្រាក់មកបើកផ្លូវថៃមកយកឥវ៉ាន់ថៃមក ។

ដារ៉ា ៖ មកលក់ដូរទៅ?

សួយៈ លក់ដូរចេះឯង តា ម៉ុកនេះគាត់ដឹងគំរោងពួកយើងខាងនេះ ។

ដារ៉ា ៖ បាទ ។

សួយៈ បានគេដឹកមកទ័ពមកដាក់នៅនេះអត់បាន១០០នាក់ទេ ។

ដារ៉ា ៖ ទ័ពណា១០០?

សួយៈ ទ័ពនិរតីមកដាក់ហ្នឹងមិនបាន១០០នាក់ទេ ។

ដារ៉ា ៖ ចឹងហេតុអីបានជាមិនអាចទាក់ទងជាមួយទ័ពនិរតី១០០នាក់ហ្នឹង?

សួយៈ ចាញ់ផ្នែកនយោបាយរបស់គេ ។

ដារ៉ា ៖ បាទ ។

សួយៈ ចាញ់នយោបាយ បើវែដែលឈ្មោះពួកខ្ញុំ វាមកភ្ជុំស្រុកតែ៥នាក់ហ្នឹង ។

ដារ៉ា ៖ អឺ ។

សួយៈ ចាប់ពួកខ្ញុំ១០០បាន ចាប់គណៈស្រុកចាប់អីអស់បាន ដាប់ហ្នឹងក៏១០នាក់ ។

ដារ៉ា ៖ ចឹងដឹងថាចាប់មេហើយ ហេតុអីកូនចៅក្រោមៗមិនអាច?

សួយៈ វាចាប់ដូចថា ចាប់ត្រីបានមិនឲ្យល្អក់ទឹក អត់ឲ្យដឹងទេ ចាប់ប្តីទៅរៀន យកប្តីទៅស្វាត់ជ្រាប បានមកយកប្រពន្ធគា វ៉ាល់និងប្រពន្ធគា ម៉ោងនេះ ខ្ញុំទៅឃើញហ្នឹងភ្នែក ។

ដារ៉ា ៖ អឺ ។

សួយៈ តែខ្ញុំភ្លេចឈ្មោះគាត់ ទុកកន្លែងលាក់ការណ៍ទៅ ថ្ងៃឡើងគេឲ្យទៅសួង សួងចេះឯងភ្លៀងប៉ប្រិចចេះ ព្រឹកឡើងឲ្យចេញទៅសួងខ្ញុំក៏ជួបគាត់ ខ្ញុំថាបងនៅនេះឯង គាត់ថាចាស ខ្ញុំនៅនេះហើយ បានខ្ញុំថាប្រពន្ធគា ម៉ោង គា វ៉ាល់តើ បានមួយរយៈកាលក្រោយមកខ្ញុំអត់ដឹងខ្ញុំមិនដឹងថា គេយកទៅសម្លាប់ចោលក៏មិនដឹងវាបាត់ដំណឹងជ្រាប ។

ដារ៉ា ៖ ចឹងក្នុងពេលហ្នឹងក្រែងយើងដឹងថា ឲ្យតែថាយកទៅរៀនទៅសូត្រហ្នឹងគឺចាប់ខ្លួនហើយ ម៉េចយើងនៅក្រោមមិនរើបំរាល់ក្លាមឬក៏វៃអាពួកនិរតីក្រោម?

សួយៈ ព្រោះវាធ្វើនយោបាយដូចជា ភូមិភាគគេមកយើងគេមកប្រជុំ ។

ដារ៉ា ៖ បាទ ។

សួយៈ គេដាក់ពត៌មានគេដាក់របាយការណ៍ បើយើងពីដើមមិញគេហៅនិរសាណាស់ ។

ដារ៉ា ៖ បាទ ។

សួយៈ គេដាក់និរសាហៅទៅ ហៅទៅប្រជុំ យើងទៅប្រជុំដល់ចូលទៅសុទ្ធតែគ្នាគេ ។

ដារ៉ា ៖ ក្រែងដឹងថា ឲ្យតែហៅទៅប្រជុំដឹងថាចាប់ខ្លួនដែរ ហើយតែទៅប្រជុំហើយតែហៅមេទៅប្រជុំបានយូរដឹងថាចាប់ខ្លួនកូនចៅហេតុអីបានជាអត់ហ៊ានរើបំរាស់បាន?

សួយៈ ដឹងតែយើងរើបំរាស់មិនរួចដូចថា វាចាលគំនិតណាស់ ។

ដារ៉ា ៖ ចង់និយាយថា ពេលបាត់មេបាត់កើយទៅមិនដឹងថាអ្នកណាដឹកនាំអីចឹង?

សួយៈ បាទ!ទេវាអត់មានគ្រាប់ម៉ាសេវ ។

ដារ៉ា ៖ អឺ ។

សួយៈ គ្រាប់មានម្នាក់បីគ្រាប់ អត់មានគ្រាប់ដឹងថាគេចាប់មេហើយ ។

ដារ៉ា ៖ បាទ ។

សួយៈ ដឹងថាគេចាប់មេបាត់ហើយ ព្រោះបាត់បីថ្ងៃហើយ ។

ដារ៉ា ៖ បាទ!ពួកខ្ញុំបានសួរនាំពូច្រើនហើយ ហើយគិតថាពត៌មានហ្នឹងច្រើនគ្រាសគ្រើលដែរ?

សួយៈ បាទ ។

ដារ៉ា ៖ ហើយនៅមានកន្លែងណាខ្វះចន្លោះអីចង់មានប្រសាសន៍បន្ថែមអីសូមអញ្ជើញ បើសិនជាពូចង់ប្រាប់ពួកខ្ញុំកន្លែងណាដែលពូដឹងហើយពួកខ្ញុំមិនបានដឹងហើយពួកខ្ញុំមិនបានសួរពូមានទេ?

សួយៈ បាទ ។

ដារ៉ា ៖ អត់មានទេ?

សួយៈ អត់មានទេ ។

ដារ៉ា ៖ ចឹងម៉ាជីវិតពូដែលបានបំរើខ្មែរក្រហមជាទ័ពអីហ្នឹង មានកន្លែងអនុស្សាវរីយ៍ណាមួយដែលពូចងចាំខ្លាំងជាងគេណាស់ គឺរឿងអីពូ?

សួយៈ ខ្ញុំចងចាំដែលនៅការពារអាងត្រពាំងថ្ម ធ្លាប់ដើរទៅទឹកវៃទឹកដើងខោ ។

ដារ៉ា ៖ អឺ ។

សួយៈ ទឹកវាខែនេះចេះទឹកវាជន់ដើរលើខ្នងទំនប់ចេះរលកវៃរបូតទៅខាងនោះ ។

ដារ៉ា ៖ បាទ ។

សួយៈ ទឹកវាប្រៀបចេះ ។

ដារ៉ា ៖ អ ។

សួយៈ សូម្បីតែខែរងាខែអីក៏មិនឲ្យយើងដក ។

ដារ៉ា ៖ បាទ ។

សួយៈ មានអីណាមានភួយណាមានតែកន្សែង ។

ដារ៉ា ៖ អ ។

សួយៈ ដើរទៅមកៗខ្លាចទំនប់បាក់ ។

ដារ៉ា ៖ ចឹងក្រោយមកពូមានបានទៅមើលឬទៅលេងទំនប់ត្រពាំងថ្មហ្នឹងដែរ?

សួយៈ អត់ដែលបានទៅឃើញទេ ។

ដារ៉ា ៖ បាទ ។

សួយៈ លែងតែអត់ស៊ីទៅក៏អត់ទៅប្រហែលជា២០ឆ្នាំហើយ ។

ដារ៉ា ៖ អឺ ។

សួយៈ ទៅម្តងមកថ្ងៃមិញហ្នឹងឯង អើតមើលទៅក៏ស្រណោះ ។

ដារ៉ា ៖ ជិះកាត់ហ្នឹងដែរ?

សួយៈ ខ្ញុំជិះកាត់ហ្នឹងមកពីថ្មពួកមកចាក់មកស្ពានទី២ ។

ដារ៉ា ៈ អឺ ។

សួយៈ អះ!ស្ពានទី៣ចាក់ចំគល់តាសុខបានចាក់ទៅទន្លេចេះ ។

ដារ៉ា ៈ ពូបើនិយាយមែនទែនទៅ ទំនប់អាងត្រពាំងថ្មពូ?

សួយៈ បាទ ។

ដារ៉ា ៈ ដែលដាក់ស្ដែងដែលធ្វើហើយហ្នឹងពូឃើញថាទំនប់ហ្នឹងមានខ្នងវាប៉ុន្មានម៉ែត្រដែលពិតប្រាកដ ដាកស្ដែងពូ?

សួយៈ ខ្នងវា៥ម៉ែត្រ ។

ដារ៉ា ៈ តែ៥ម៉ែត្រទេ?

សួយៈ បាទ!តែ៥ម៉ែត្រទេ ហើយខ្នងទើបធ្វើថ្មីរួចណាស់ ។

ដារ៉ា ៈ បាទ ។

សួយៈ ហើយវារីកដល់ដូចជាសព្វថ្ងៃនេះខ្ញុំអត់ដឹងទេ ។

ដារ៉ា ៈ អឺ ។

សួយៈ បើខ្នងវាកាលចាប់ផ្ដើមធ្វើគេដាក់៥ម៉ែត្រ ។

ដារ៉ា ៈ ព្រោះចេះខ្ញុំសួរពូសេងពូ?

សួយៈ បាទ ។

ដារ៉ា ៈ ពូសេងថាផែនការវាដំបូងហ្នឹងគឺខ្នងទំនប់២៥ម៉ែត្រ ហើយបាតទំនប់ក្រោមចេះ៤០ម៉ែត្រ ហើយកំពស់វាទៅតាមកន្លែងទួលនិងកន្លែងទាប ។

សួយៈ បាទ ។

ដារ៉ា ៈ បើកន្លែងទួលលើកតែបីម៉ែត្រទេ ហើយបើកន្លែងត្រពាំងអីវាអាចថាពី៤ទៅ៥ទៅ៦ម៉ែត្រអី ចឹង ។

សួយៈ បាទ ។

ដារ៉ា ៈ ប៉ុន្តែខ្នងទំនប់គឺ២៥ម៉ែត្រអាហ្នឹង តើពូយលថាអាហ្នឹងវាពិតប្រាកដចឹងមែនដែលនៅពេល ឃើញទំនប់ហ្នឹងហើយដាក់ស្ដែងពូ?

សួយៈ ព្រោះខ្ញុំឃើញកាលលើកហើយវាមិនបាន២៥ទេ ព្រោះបើយើងវៀសឡានបានតែចេះឯង ។

ដារ៉ា ៈ តែឡានពីរទេ?

សួយៈ បាទ!ឡានពីរ វៀសគ្នាបានម៉ាស្រួលណាស់ ។

ដារ៉ា ៖ បាទ ។

សួយៈ បានខ្ញុំមើលទៅព្រោះវាចងខ្សែចេះ ចងខ្សែទម្លាក់ចេះបានគេចាក់យកខ្នងទំនប់ឲ្យស្មើណាស់ ។

ដារ៉ា ៖ បាទ ។

សួយៈ ស្មើរួចបានសួរខ្មោចអាឆ្កួយនេះ អាឆ្កួយខ្សែនេះប៉ុន្មានម៉ែត្រខ្សែនេះ វាថា៥ម៉ែត្របង ។

ដារ៉ា ៖ ចឹង?

សួយៈ បាទ!ចឹងបានខ្ញុំថា៥ម៉ែត្រ ដីគាត់ថាចេះឯងដីទំនៀបវាបាក់អូរយើងអែបស្ពានទី១អានោះ កំពស់វាចង់៧ទៅ៨ម៉ែត្រណាស់ ។

ដារ៉ា ៖ អឺ ។

សួយៈ ឡើងចេះឯង ។

ដារ៉ា ៖ អ ។

សួយៈ អានោះកងពិសេសលើកណាស់អានោះ ។

ដារ៉ា ៖ កងពិសេស?

សួយៈ បាទ!ៗកងពិសេសសុទ្ធវែករត់៨អំវែកមួយម៉ែត្រគីប ។

ដារ៉ា ៖ អឺ ។

សួយៈ បក្តីវាស្មាទោសចង់ប៉ុននេះណាស់ ។

ដារ៉ា ៖ បាទ ។

សួយៈ បក្តីស្រីៗវែកអត់មានប្រុសសុទ្ធតែស្រី ។

ដារ៉ា ៖ អឺ ។

សួយៈ ប៉ុនមាឌវាប៉ុនមាឌនាងចេះឯង ។

ដារ៉ា ៖ អឺ ។

សួយៈ ព្រោះវាហូបឆ្អែតឆាត់ក៏វែកលឿនណាស់ ។

ដារ៉ា ៖ បាទ ។

សួយៈ បើផុតពីនោះកងស្មើដើងទៅបានមួយកំប៉ុង ធ្វើធម្មតា ។

ដារ៉ា ៖ បាទ ។

សួយៈ បក្តីប៉ុនៗនេះ ។

ដារ៉ា ៖ បាទ ។

សួយៈ ធ្វើធម្មតា ។

ដារ៉ា ៖ ចឹងពួកខ្ញុំដូចជាអត់មានសំនួរអីសួរពូថែមទៀតទេ ដូចជាអស់ហើយ ។

សួយៈ បាទ ។

ដារ៉ា ៖ ហើយពួកខ្ញុំសូមអរគុណពូច្រើនដែលបានអនុញ្ញាតិឲ្យពួកខ្ញុំធ្វើបទសម្ភាសន៍អំពីជីវិតនៅត្រពាំងថ្មអីហ្នឹងចឹងណាស់ពូ ។

សួយៈ បាទ ។

ដារ៉ា ៖ ហើយខ្ញុំសូមអរគុណពូច្រើនពូ ។

សួយៈ បាទ ។

ដារ៉ា ៖ ខ្ញុំសូមបញ្ចប់ការសម្ភាសខ្ញុំត្រឹមប៉ុណ្ណឹងពូណាស់ ។

សួយៈ បាទ ។

ដារ៉ា ៖ បាទ! អរគុណពូ ។

សួយៈ បាទ ។

**ចប់**